# ដំណាំឈើហូបផ្លែ



## គោលការណ៍បច្ចេកទេស និងបទពិសោធន៍ជាក់ស្តែង

យ៉ង សាំងកុមារ និង ពាន សុខា

CEDAC

២០១០

# ដំណាំឈើហូបផ្លែ

ចងក្រងដោយ : បណ្ឌិត យ៉ង សាំងកុមារ និង ពាន សុខា

បោះពុម្ពផ្សាយដោយ : មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក)

រក្សាសិទ្ធិដោយ : អង្គការ សេដាក

បោះពុម្ពចំនួន ២០០០ ច្បាប់ ២០១០

# អារម្ភកថា

នៅប្រទេសកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ ការងារកសិកម្មមានការវិវត្តន៍ និងរីកចំរើនលើការស្រាវជ្រាវ និងសាកល្បងជាបន្តបន្ទាប់ ។ ដោយយោងទៅលើការវិវត្តន៍នេះ ខ្ញុំបានខិតខំចងក្រងសៀវភៅ "**ឈើហូបផ្លែ**" នេះដើម្បីជួយដល់ការស្រាវជ្រាវ និងសាកល្បងរបស់បងប្អូនកសិករ ដែលមានបំណងចង់ដាំឈើហូបផ្លែឱ្យបានទិន្នផលខ្ពស់ ។

ដំណាំឈើហូបផ្លែដើរតួនាទីយ៉ាងសំខាន់នៅក្នុងសួនដំណាំគ្រួសារ ជួយដល់សេដ្ឋកិច្ចគ្រួសារ និងផ្តល់នូវអាហារបំប៉នយ៉ាងប្រសើរ ដល់ការលូតលាស់រាងកាយមនុស្ស ។

នៅប្រទេសកម្ពុជាលក្ខណៈអាកាសធាតុមានភាពសមស្របបំផុត សំរាប់ការដាំឈើហូបផ្លែដូចជា សីតុណ្ហភាពមធ្យម និងមានសំណើមខ្ពស់ស្ទើរពេញមួយឆ្នាំ រីឯពន្លឺក៏គ្រប់គ្រាន់ កំពស់ទឹកភ្លៀងមានលក្ខណៈសមស្របគ្រប់តំបន់ ។ ការដាំឈើហូបផ្លែត្រូវចំណាយពេលយូរ ទើបទទួលបានផល ប៉ុន្តែផលដែលយើងទទួលបានក៏មានរយៈពេលយូរដែរ ។

សៀវភៅឈើហូបផ្លែនេះចងក្រងឡើងដោយចែកចេញជា ៤ជំពូកធំៗ មានដូចជាបច្ចេកទេសដាំដុះដំណាំឈើហូបផ្លែ ការបំបែកពូជ បទពិសោធន៍ជាក់ស្តែងរបស់កសិករ និងសរុបបច្ចេកទេសសំខាន់ៗក្នុងការដាំឈើហូបផ្លែ ។

សៀវភៅនេះត្រូវបានរៀបរៀងឡើងដោយរួមបញ្ចូលនូវទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែងរបស់កសិករនៅក្នុងលក្ខខណ្ឌនៃប្រទេសកម្ពុជា ។

ខ្ញុំសង្ឃឹមថាសៀវភៅនេះជាទុនមួយចូលរួមចំណែកជួយបងប្អូនកសិករក៏ដូចជាអ្នកផ្សព្វផ្សាយបច្ចេកទេសដើម្បីផ្សព្វផ្សាយដល់ស្រទាប់កសិករ ដែលធ្វើការលើការងារបង្កបង្កើនផល ។

ខ្ញុំក៏សូមស្វាគមន៍ជានិច្ច ចំពោះការចូលរួមចំណែករបស់លោក-លោកស្រី ក្នុងការជួយកែលំអសៀវភៅបច្ចេកទេសនេះដើម្បីឱ្យកាន់តែប្រសើរថែមទៀត ហើយក៏សូមថ្លែងអំណរគុណដល់អ្នកស្រី ស៊ិន អង្គារសាធ និងលោក កន រតនៈ ដែលបានជួយវាយ អត្ថបទ និងរចនាសៀវភៅនេះ ។

ពាន សុខា


ម.ព.ឯ.ក AIDOC
Code: 109-013
Date:
Donated by:

# មាតិកាអត្ថបទ

អារម្ភកថា

**ជំពូក១: បច្ចេកទេសដាំដុះដំណាំឈើហូបផ្លែ** ............ ១

១.១. ការជ្រើសរើសទីតាំងសំរាប់ដាំ ............ ១

១.២. លក្ខណៈអាកាសធាតុ និងដីរបស់ដំណាំឈើហូបផ្លែ ............ ២

១.៣. ការរៀបចំដីដាំ ............ ២

ក. ការដាំជារាង ៤ជ្រុងការេ ............ ៣

ខ. ការដាំជារាង ៤ជ្រុងទ្រវែង ............ ៣

គ. ការដាំជារាងមុំចង្រ្កាន ឬ៤ជ្រុង ............ ៤

១.៤. ការដាំឈើហូបផ្លែ ............ ៤

១.៤.១.សំភារៈចាំបាច់សំរាប់ប្រើ ............ ៤

១.៤.២.ការដាំនិងបណ្តុះកូន ............ ៤

ក. ការបណ្តុះកូន ............ ៤

ខ. ការជីករណ្តៅ ............ ៥

គ. ការដកកូនដាំ ............ ៧

ឃ. ចន្លោះគុម្ពដាំ ............ ៨

១.៥. ការថែទាំ ............ ៩

១.៥.១. របៀបដាក់ជី និងស្រោចទឹកលើដំណាំឈើហូបផ្លែ ............ ៩

១.៥.២. ការថែទាំផ្សេងៗ ............ ១០

១.៥.៣. ការកាត់តែងមែក ............ ១១

ក. ពេលវេលានៃការកាត់តែងមែក ............ ១១

ខ. ប្រភេទនៃការកាត់តែងមែក ............ ១១

**ជំពូក២: ការបំបែកពូជ** ............ ១៤

២.១. ការដាំឬពង្រីកពូជដោយផ្លែ ............ ១៤

២.២. ការដាំឬពង្រីកពូជដោយគ្រាប់ ............ ១៤

២.៣. ការដាំឬពង្រីកពូជដោយកូន ............ ១៩

២.៤. ការបំបែកពូជដោយមែក ............ ១៩

២.៤.១. ការសាកមែក (Layering) ............ ១៩

២.៤.២. ការភ្ជាប់មែក (Approach Grafting) ............ ១៩

២.៤.៣. ការភ្ជាប់ភ្នែក (Bud Grafting)............................................................................... ២១

**ជំពូក៣: បទពិសោធន៍ជាក់ស្តែងរបស់កសិករក្នុងការដាំឈើហូបផ្លែ**............................................. ២៦

៣.១. បទពិសោធន៍ដាំចេកអំបូង............................................................................... ២៦

៣.២. បទពិសោធន៍ដាំស្វាយកែវរមៀត........................................................................ ២៨

៣.៣. បទពិសោធន៍ដាំល្ហុងឱ្យបានផ្លែច្រើន ............................................................... ៣២

៣.៤. បទពិសោធន៍ដាំក្រូចពោធិសាត់មានរស់ជាតិផ្អែម............................................... ៣៥

៣.៥. បទពិសោធន៍ដាំសាវម៉ាវ................................................................................. ៣៨

៣.៦. បទពិសោធន៍ដាំមៀនឱ្យបានផ្លែច្រើន.............................................................. ៤០

៣.៧. បទពិសោធន៍ដាំខ្នុរឱ្យបានផ្លែច្រើន.................................................................. ៤២

៣.៨. បទពិសោធន៍ដាំត្របែកឱ្យបានផ្លែច្រើន ............................................................. ៤៣

៣.៩. បទពិសោធន៍ដាំដូងឱ្យបានផ្លែច្រើន.................................................................. ៤៦

**ជំពូក៤: សរុបបច្ចេកទេសសំខាន់ៗក្នុងការដាំឈើហូបផ្លែ**.......................................................... ៤៨

# ជំពូក ១

# បច្ចេកទេសដាំដុះដំណាំឈើហូបផ្លែ

## ១.១. ការជ្រើសរើសទីតាំងសំរាប់ដាំឈើហូបផ្លែ

ដំណាំឈើហូបផ្លែយើងអាចដាំនៅគ្រប់កន្លែងដូចជា ដីខ្ពង់រាប ដីវាលរាប ដីជំរាលភ្នំ ។ល។

- ដីខ្ពង់រាប ជាដីមិនលិចទឹក និងជាដីដែលមានអំណោយផលល្អបំផុតសំរាប់ដំណាំឈើហូបផ្លែ។ ការដាំឈើហូបផ្លែនៅលើដីខ្ពង់រាប យើងគ្រាន់តែចំណាយពេលកាប់ឆ្ការព្រៃ និងកាប់គាស់គល់ ហើយរៀបចំរណ្តៅដាំ។



- ដីវាលរាបជាដីដែលធ្លាប់លិចទឹក និងជាំទឹក។ ដូច្នេះមុនដាំយើងត្រូវលើករង ឬលើកភ្លឺឱ្យខ្ពស់ការពារទឹកជំនន់។



➢ ចំពោះដីជំរាលជើងភ្នំ ជាដីដែលស្រស់ទឹកល្អ មិនដាំទឹក ដីប្រភេទនេះយើងគ្រាន់តែកាប់ឆ្ការព្រៃ គាស់គល់ឈើ រួចរៀបចំរណ្តៅដាំតែម្តង ។



## ១.២. លក្ខណៈអាកាសធាតុ និងដីរបស់ដំណាំឈើហូបផ្លែ

អាកាសធាតុជាកត្តាកំណត់នូវការលូតលាស់ និងទិន្នផលដំណាំ ។ តើចំពោះដំណាំឈើហូបផ្លែត្រូវការលូតលាស់ក្រោមលក្ខខណ្ឌអាកាសធាតុបែបណា?

➢ សីតុណ្ហភាពខ្ពស់បំផុតសំរាប់ការលូតលាស់ឈើហូបផ្លែគឺ ៣៨អង្សាសេ

➢ សីតុណ្ហភាពមធ្យម ២៥ អង្សាសេ

➢ សីតុណ្ហភាពទាបបំផុត ១២ អង្សាសេ ។

ជាទូទៅសីតុណ្ហភាព ដែលអាចឱ្យដំណាំឈើហូបផ្លែអាចដុះ និងលូតលាស់បានគឺពី ១២-៣០ អង្សាសេ ។ ប៉ុន្តែសីតុណ្ហភាព ដែលល្អប្រសើរបំផុតសំរាប់ដំណាំឈើហូបផ្លែគឺ ២៥ អង្សាសេ ។

ចំពោះដី ជាទូទៅដំណាំឈើហូបផ្លែត្រូវការលូតលាស់លើដី ដែលមានអាស៊ីតខ្សោយ ទៅណឺត (PH 6-7) ។ ដីដែលមានចំរោះទឹកល្អ មិនដាំទឹក មានធាតុមមោកច្រើន និងមានដីជាតិនៅជំរៅជ្រៅ ។

## ១.៣. ការរៀបចំដីដាំ

ក្នុងការរៀបចំដីដាំឈើហូបផ្លែ នៅក្នុងចំការធំៗ យើងត្រូវរៀបចំជាប្រព័ន្ធដាំដុះដើម្បីឱ្យមានលក្ខខណ្ឌងាយស្រួលក្នុងការចូលទៅថែទាំដូចជា ធ្វើស្មៅ ពូនគល់ កាត់តែងមែក ។ល។ ចំពោះប្រព័ន្ធនៃការដាំដុះទាំងនោះរួមមានៈ

➢ ការដាំជារាង ៤ជ្រុងការេ

➢ ការដាំជារាង ៤ជ្រុងទ្រវែង

- ការដាំជារាង មុំចង្ក្រាន
- ការដាំជារាង កាំជណ្ដើរ ។

ប្រព័ន្ធដាំដុះទាំង ៤នេះមានលក្ខណៈសម្បត្តិខុសៗគ្នាដូចជា:

**ក. ការដាំជារាង ៤ ជ្រុងការេ**




ប្រព័ន្ធនេះមានចន្លោះពីដើមមួយ ទៅដើមមួយស្មើពីជួរមួយទៅជួរមួយ ។ ប្រព័ន្ធនេះងាយស្រួលក្នុងការភ្ជួរ បំផុសដី ប៉ុន្តែសល់ដីចោលច្រើន មិនបានយកមកប្រើការ ។ ប៉ុន្តែយើងអាចយកកូនឈើរួមផ្សំមកដាំចន្លោះកណ្ដាលគឺ ដំណាំរួមផ្សំ ដែលមានអាយុតិច ទំរង់មែកទាប (ដើមទាប) ហើយតូចនៅចន្លោះដំណាំគ្រឹះ ។

**ខ. ការដាំជារាង ៤ ជ្រុងទ្រវែង**

ប្រព័ន្ធដាំដុះនេះមានចន្លោះពីដើមមួយទៅដើមមួយជិតជាងពីជួរមួយទៅជួរមួយទៀត ។ ប៉ុន្តែអាចប្រើប្រាស់ ដីដាំដុះដំណាំរួមផ្សំផ្សេងទៀតនៅចន្លោះជួរបាន ។



គ. ការដាំជារាងមុំចង្រ្កាន ឬ ៥ជ្រុង

ប្រព័ន្ធនេះអាចបង្កើនចំនួនដើមបាន ១៥ ដើមក្នុង ១០០ដើម ហើយប្រព័ន្ធដាំដុះនេះត្រូវបានគេនិយមដាំច្រើន។



## ១.៤. ការដាំឈើហូបផ្លែ

### ១.៤.១. សំភារៈចាំបាច់សំរាប់ប្រើ

ក្នុងការដាំកូនឈើយើងត្រូវត្រៀមសំភារៈមួយចំនួន សំរាប់ប្រើមានដូចជាៈ ចបកាប់ ចបជីក បង្គី ធុងស្រោច។ នៅពេល ដែលកូនឈើធំយើងត្រូវការកាត់តែងមែកដោយប្រើសំភារៈមួយចំនួនដូចជា កន្ត្រៃ រណាតូចធំ កាំបិតផ្កាក់ កណ្តៀវ ។ល។




សំភារៈសំរាប់កាត់តែងមែក

### ១.៤.២. ការដាំនិងបណ្តុះកូន

ក. ការបណ្តុះកូន

ការបណ្តុះកូនយើងត្រូវរៀបចំជាថ្នាលបណ្តុះ ដែលមានទីតាំងនៅលើដីទួលមិនលិចទឹក និងនៅជិតប្រភពទឹកងាយស្រួលក្នុងការស្រោចស្រពនៅរដូវក្តៅ។ ថ្នាលបណ្តុះត្រូវមានគម្របពីធម្មជាតិ ដូចជាស្លឹកដូង ឬសំណាញ់បៃតងដើម្បីបន្ថយកំដៅពេលថ្ងៃ កុំឱ្យរំហួតលឿន និងកុំឱ្យកូនឈើស្វិតស្រពោន។ ក្រៅពីនេះថ្នាលត្រូវមានទំហំតូចល្មម ដែលមានទទឹង ១-១.២ ម៉ែត្រ និងបណ្តោយ ២-២.៥ ម៉ែត្រ ដើម្បីងាយស្រួលក្នុងការបណ្តុះ ឬថែទាំ។

ជាទូទៅគេច្រើនបណ្តុះកូនឈើហូបផ្លែដាក់នៅក្នុងថង់។ ចំពោះការរៀបចំដីដាក់ថង់ត្រូវរៀបចំៈ

- ដីឥដ្ឋ ឬដីដំបូកត្រូវមានប្រហែលពី ២០-២៥ ភាគរយ
- ដីហ្មត់ ឬកំប៉ុស្តហ្មត់ប្រហែលពី ១០-១៥ ភាគរយ
- ដីខ្សាច់ ឬដីស្រែត្រូវមានពី ៦០-៧០ ភាគរយ។

ប្រសិនបើបរិមាណនេះមានការប្រែប្រួល ដូចជាដីឥដ្ឋច្រើនពេកធ្វើឱ្យដីជាំទឹក កូនឈើអាចងាប់បាន។ ដូចគ្នាដែរប្រសិនជាដីខ្សាច់ច្រើនពេក ធ្វើឱ្យទឹកហូរចេញច្រើន ព្រោះដីខ្សាច់គ្មានសមត្ថភាពរក្សាទឹកបានយូរ ហើយប្រសិនជាដីមមោក ឬកំប៉ុស្តច្រើនពេកធ្វើឱ្យកូនឈើហូបផ្លែ ដុះលូតលាស់ល្អខ្លាំង ប៉ុន្តែនៅពេលយើងយកវាទៅដាំនៅក្រៅថង់ ហើយជាប់កន្លែងដែលមិនសូវមានជីជាតិផងនោះ ធ្វើឱ្យកូនឈើអន់ ហើយអាចងាប់បាន។

**ខ. ការជីករណ្តៅ**

ជាទូទៅទំហំរណ្តៅដាំឈើហូបផ្លែប្រែប្រួលទៅតាមប្រភេទដើមឈើ ដូចជាៈ

- ខ្នាតធំ ១ ម៉ែត្រ x ១ ម៉ែត្រ
- ខ្នាតមធ្យម ៧៥ ស.ម x ៧៥ ស.ម
- ខ្នាតតូច ៥០ ស.ម x ៥០ ស.ម។

យើងត្រូវចងចាំថា ការជីករណ្តៅធំធ្វើឱ្យរុក្ខជាតិដុះលូតលាស់បានល្អព្រោះរណ្តៅធំយើងអាចដាក់ជីបានច្រើន ។

☞ ចំពោះវិធីជីករណ្តៅត្រូវរៀបចំឱ្យបានពី ១-២ខែ មុនពេលដាំ។ ក្នុងការជីកត្រូវបែងចែកជា ៣ស្រទាប់ដោយឡែកពីគ្នា។

- អាចម៍ដីដែលជីកជំរៅ ២៥ ស.ម ដាក់ដោយឡែក (ដីស្រទាប់លើ)
- អាចម៍ដីដែលជីកជំរៅ ៥០ ស.ម ដាក់ដោយឡែក (ដីស្រទាប់បន្ទាប់ ឬ ស្រទាប់កណ្តាល)
- អាចម៍ដីដែលជីកជំរៅ ៧៥ ស.ម ដាក់ដោយឡែក (ដីស្រទាប់ក្រោម)

☞ ការលុបរណ្តៅ និងការប្រើជីទ្រាប់បាត

ចំពោះការលុបរណ្តៅត្រូវធ្វើភ្លាមបន្ទាប់ពីការជីករួច ទៅតាមស្រទាប់ដី ។ ការប្រើជីទ្រាប់បាតរណ្តៅមាន ២របៀបៈ

<u>របៀបទី១ៈ</u>

- ដីស្រទាប់ក្រោមដាក់ខាងក្រោមបាតរណ្តៅលាយជាមួយជីកំប៉ុស្ត ៣-៥បង្គី
- ដីស្រទាប់កណ្តាលដាក់លាយជាមួយជីកំប៉ុស្ត ៣-៥បង្គី

- ដីស្រទាប់លើ លាយជាមួយលាមកសត្វ ៣-៥បង្គី។




របៀបទី២:

យកគ្រួសឬថ្មដាក់នៅបាតរណ្តៅ ហើយលុបដីវិញទៅតាមស្រទាប់ដីនិមួយៗ គឺស្រទាប់ក្រោម ដាក់ក្រោម ស្រទាប់កណ្តាលដាក់កណ្តាល និងស្រទាប់លើដាក់លើ និងយកដីកន្លែងផ្សេងលាយជាមួយដីកំប៉ុស្ត ឬដីលាមកសត្វ ៣ បង្គីដាក់ពូនឱ្យខ្ពស់។

សំគាល់

- បើដីនៅបាតរណ្តៅមានកណ្តៀរត្រូវដាក់ដីខ្សាច់ ១-២បង្គីលាយជាមួយផេះ ១បង្គី
- ការលប់រណ្តៅ យើងត្រូវលប់ឱ្យបានខ្ពស់ជាងមាត់រណ្តៅ ២ ទៅ ៣តឹក ទើបរណ្តៅមិនដក់ទឹក រុក្ខជាតិមិនមានជំងឺជាំទឹក
- ក្រោយពីលុបរណ្តៅតាមស្រទាប់ដី ហើយត្រូវច្របល់ដីជាមួយដីឱ្យស្មើល្អ
- រណ្តៅដែលលុបរួចហើយត្រូវយកកំទេចស្មៅ ឬក៏ចំបើងគ្របពីលើ ហើយស្រោចទឹកពី ៧-១០ ថ្ងៃម្តង។



រណ្តៅរៀបចំល្អ



រណ្តៅរៀបចំមិនត្រឹមត្រូវ

គ. ការដកកូនដាំ

ជាទូទៅពេលវេលា ដែលសមស្របសំរាប់ការដាំកូនឈើហូបផ្លែគឺនៅដើមរដូវភ្លៀង និងចុងរដូវភ្លៀងជាពេលវេលាល្អបំផុតសំរាប់ការដាំកូនឈើ ។

មានកូនឈើជាច្រើន ដែលបានដាំហើយត្រូវងាប់ទៅវិញ ក្រោយពីបានយកទៅដាំនៅក្នុងចំការ ។ ការងាប់នេះបណ្តាលមកពីការអនុវត្តន៍មិនត្រឹមត្រូវដូចជា ដកកូនតូចពេក ឬធំពេក ឬដាច់ឫស ។ល ។ ដូច្នេះក្នុងការដកកូនឈើដាំយើងត្រូវយកចិត្តទុកដាក់ និង ត្រៀមនូវសំភារៈមួយចំនួនដូចខាងក្រោមៈ

- កូនឈើដែលមានសុខភាពល្អ មិនមានការបំផ្លាញពីជំងឺ និងសត្វល្អិត និងមានកំពស់ពី ៣០-៥០ សង្ទីម៉ែត្រ
- កុំស្រោចទឹកនៅថ្ងៃដែលដកកូនពីថ្នាល ឬចង់ទៅដាំ ព្រោះធ្វើឱ្យដីស្អិតជាប់ឫសពិបាកក្នុងការដាំ
- សំភារៈដែលត្រៀមសំរាប់ការដាំមាន បន្ទាត់ខ្នាត បង្គោលឈើ កូនឈើ ខ្សែ និងចបជីក
- ចំពោះការដាំត្រូវជីកចំកណ្តាលរណ្តៅជំរៅពី ១៥-២០ ស.ម ហើយទុកអាចម៍ដី នៅក្បែរនោះសំរាប់លុប វិញ។ ត្រូវធ្វើកំពែងបណ្តោះអាសន្នមួយក្រោយពេលដាំ សំរាប់ឱ្យទឹកដក់ ហើយជ្រាបនៅពេលស្រោច
- កូនឈើត្រូវដាំដោយដាក់គល់វាឱ្យស្មើនឹងផ្ទៃដី ហើយចំកណ្តាលរណ្តៅ ដាក់ដើមដាំឱ្យត្រង់ រួចលុបដីឱ្យណែនល្មម ស្រោចទឹកឱ្យជោគ ហើយចងដើមឱ្យជាប់នឹងបង្គោលឈើ ។



រូបភាព ការដាំកូនឈើ

## ឃ. ចន្លោះគុម្ពដាំ

ចន្លោះគុម្ពនៃការដាំឈើហូបផ្លែគឺអាស្រ័យទៅលើប្រភេទឈើហូបផ្លែ និងសភាពដី ។ ខាងក្រោមជាឧទាហរណ៍ខ្លះៗនៃចន្លោះគុម្ពសំរាប់ការដាំឈើហូបផ្លែៈ

| ឈ្មោះឈើហូបផ្លែ | ចន្លោះគុម្ព |
|---|---|
| ម្នាស់ | ៣៥ ស.ម x ៣៥ ស.ម |
| ចេក | ៣ ម x ៣ ម |
| ទាប | ៣ ម x ៣ ម |
| ក្រូច | ៤ ម x ៤ ម ឬ ៦ ម x ៦ ម |
| ត្របែក | ៤ ម x ៤ ម ឬ ៥ ម x ៥ ម |
| ដូងតឿ | ៥ ម x ៥ ម |
| ដូងធំ | ៦ ម x ៦ ម ឬ ៧ ម x ៧ ម ឬ ៨ ម x ៨ ម ឬ ៩ ម x ៩ ម |
| ល្មុត | ៦ ម x ៦ ម |
| ជំពូ | ៦ ម x ៦ ម ឬ ៧ ម x ៧ ម ឬ ៨ ម x ៨ ម |
| ស្វាយចន្ទី | ៨ ម x ៨ ម |
| មង្ឃុត | ១០ ម x ១០ ម |
| កំពីងរាជ | ១០ ម x ១០ ម |
| អំពិលផ្អែម | ១២ ម x ១២ ម |
| ដើមមាន | ១២ ម x ១២ ម |
| គូលែន | ៨ ម x ៨ ម ឬ ៩ ម x ៩ ម ឬ ១០ ម x ១០ ម ឬ ១២ ម x ១២ ម |
| ខ្នុរ ទឹកដោះគោ | ៨ ម x ៨ ម ឬ ៩ ម x ៩ ម ឬ ១០ ម x ១០ ម |
| ស្វាយដាំគ្រាប់, ធូរេន | ១០ ម x ១០ ម ឬ ១១ ម x ១១ ម ឬ ១២ ម x ១២ ម |
| សាវម៉ាវ | ១០ ម x ១០ ម ឬ ១២ ម x ១២ ម |
| ស្វាយបំពៅ | ៦ ម x ៦ ម ឬ ៧ ម x ៧ ម ឬ ៨ ម x ៨ ម |
| ម្កាក់ធំ | ៦ ម x ៦ ម ឬ ៧ ម x ៧ ម ឬ ៨ ម x ៨ ម |
| ម្កាក់តូច | ២ ម x ២ ម ឬ ៣ ម x ៣ ម |
| ពុទ្រា | ៦ ម x ៦ ម |

## ១.៥. ការថែទាំ

### ១.៥.១. របៀបដាក់ជី និងស្រោចទឹកលើដំណាំឈើហូបផ្លែ

បទពិសោធន៍កន្លងមក បានបង្ហាញឱ្យឃើញថា ការធ្វើជាចង្អូរនៅជុំវិញដើមឈើហូបផ្លែសំរាប់ដាក់ជី និងស្រោចទឹកអាចជួយឱ្យដើមឈើហូបផ្លែលូតលាស់ និងបានផលល្អ ។

១) យើងត្រូវជីកចង្អូរជារាងរង្វង់ជុំវិញគល់ឈើ ដោយកន្លែងដែលជីកចង្អូរត្រូវនៅចំកន្លែងចុងមែករបស់ដើមឈើ ឬកូនឈើនោះ ពីព្រោះជាកន្លែងដែលឫសលូតលាស់ដល់ ហើយជាកន្លែងដែលប្រជុំនូវប្រព័ន្ធ ឫសដែលស្រូបយកជីជាតិ និងទឹកពីដី ។ ទំហំរបស់ចង្អូរគឺទទឹង ១ តឹកកន្លះ ទៅ ២ តឹក ហើយជំរៅប្រហែល ១ តឹកកន្លះ ទៅ ២ តឹកដែរ ។





ការជីកចង្អូរជុំវិញដើមឈើ

២) បន្ទាប់មកយើងប្រមូលយកស្លឹកឈើលាមកសត្វ និង ជីធម្មជាតិផ្សេងៗ យកមកដាក់បំពេញតាមចង្អូរនេះ។ នៅពេលចង្អូរពេញ យើងអាចយកដីមកចាក់បន្ថែមពីលើថែមបន្តិចៗ។ យើងក៏អាចយកផេះលាយជាមួយដីបន្ថែមបានដែរ ។



ការប្រមូលស្លឹកឈើនិងលាមកសត្វចាក់បំពេញចង្អូរ

៣) នៅពេលយើងស្រោចទឹកបន្ថែម យើងស្រោចតែតាមចង្អូរបានហើយ ។ ប្រសិនបើយើងមានជីទឹកសំរាប់ស្រោចជាការមួយល្អណាស់ជាពិសេសនៅពេលមុនឈើរៀបចេញផ្កា ឬកំពុងចេញផ្កាបានបន្តិច ។



ការស្រោចទឹកដើម្បីឱ្យសារធាតុសរីរាង្គឆាប់ផុយរលួយ

៤) ក្នុងរយៈពេល ២ ទៅ ៣ អាទិត្យក្រោយមក សារធាតុសរីរាង្គ ត្រូវបានពុកបន្តិចម្តងៗ ពេលនោះដីក្នុងរណ្តៅក៏ស្រុតចុះដែរ។ ដូចនេះ យើងត្រូវឧស្សាហ៍ដាក់ជីបន្ថែម ។



ដើមឈើទទួលផលផ្លែផ្កា

ដើម្បីចង់ដឹងថា តើវិធីសាស្ត្រដូចរៀបរាប់ខាងលើអាចជួយនាំមកផលល្អ សូមបងប្អូនកសិករធ្វើ ការជ្រើសរើសឈើហូបផ្លែ (ឧ. ត្របែក ក្រូចឆ្មារ ពុទ្រា។ល។) ចំនួន ៤ ទៅ ៥ដើម ធ្វើការពិសោធន៍ ហើយធៀបជាមួយអ្វី ដែលជាទំលាប់របស់បងប្អូន។ យើងសង្ឃឹមថា ការពិសោធន៍របស់បងប្អូននឹងបាន លទ្ធផល ល្អជាក់ជាមិនខាន ។

### ១.៥.២. ការថែទាំផ្សេងៗ

ក្រៅពីការដាក់ជី និងស្រោចទឹកនៅមានការថែទាំផ្សេងទៀតដូចជាៈ

- ក្រោយពីដាំហើយត្រូវយកបង្គោលចងទប់ដើមកុំឱ្យខ្យល់បក់យោគដើម
- ត្រូវគ្របគល់ដោយកំទេចចំបើង ស្លឹកឈើងាប់ ឬស្មៅ
- ត្រូវថែទាំកំពែងទប់ទឹកនៅមាត់រណ្តៅកុំឱ្យធ្លាយ (នៅពេលកូនឈើទើបដាំ ឬនៅតូច)
- កប់គល់កូនឈើត្រូវឱ្យស្មើនឹងផ្ទៃដី

- ត្រូវជំរះស្មៅចង្រៃនៅក្បែររណ្តៅចោល
- ដើមត្រូវលាបទឹកកំបោរសការពារមេរោគរាតត្បាត នៅកន្លែងមុខកាត់ ដែលយើងបានកាត់
- ត្រូវកាត់មែកងាប់ៗចោល និងបេះខ្នែង ដែលដុះចេញពីដើមមេចោល
- ត្រូវខុសប្រាហ៍ពិនិត្យមើលការបំផ្លាញរបស់សត្វល្អិត ដោយបេះដង្កូវចោល ។

### ១.៥.៣. ការកាត់តែងមែក

ការកាត់តែងមែកជាការងារសំខាន់បំផុតសំរាប់ដំណាំឈើហូបផ្លែ ហើយគោលបំណងនៃការកាត់តែងមែកនេះគឺធ្វើយ៉ាងណាកុំឱ្យស្លឹក និងមែកក្រាស់ណែនពេក ដើម្បីឱ្យពន្លឺថ្ងៃចាំងចូលដល់គល់មែក ដើម បានយ៉ាងតិច ២៥-៣០ ភាគរយ ។

ចំពោះប្រភេទមែកដែលត្រូវកាត់មាន មែកងាប់ មែកមានជំងឺ មែកបាក់ មែកមានបញ្ចើក្អែក មែកអំពង់ មែកជិតគ្នា មែកកកិតគ្នា និងមែកដែលមិនអាចទទួលពន្លឺថ្ងៃបាន ។ល ។

**ក. ពេលវេលានៃការកាត់តែងមែក**

គេនិយមធ្វើការកាត់តែងមែកក្រោយពេលប្រមូលផលរួច ឬដើមរដូវវស្សា (ក្រោយរដូវភ្លៀង) ។

- ការកាត់តែងមែកត្រូវកាត់ក្រោយពេលប្រមូលផលរួចថ្មីៗ មួយសប្តាហ៍ ។ រដូវប្រមូលផលជារដូវក្តៅ ដើមឈើត្រូវការអាហារមកចិញ្ចឹមដើមមែកច្រើន ដូច្នេះការកាត់តែងមែកព្រមជាមួយការដាក់ជី ស្រោចទឹកជំរុញឱ្យដើមឈើបែកមែកថ្មីៗ លូតលាស់បានលឿន
- ចំពោះការកាត់តែងមែក ក្រោយរដូវភ្លៀងជាពេលវេលាល្អ ព្រោះក្នុងកំឡុងរដូវភ្លៀងដើមឈើលូតលាស់មែកខ្នែងស្លឹកច្រើនហួសពីសេចក្តីត្រូវការ ។ ករណីនេះអាចបណ្តាលឱ្យកើតជំងឺផ្សិត និងសម្បុណិសត្វល្អិតបំផ្លាញ ។

ដូច្នេះការកាត់តែងមែកក្នុងរដូវនេះ ជួយកាត់បន្ថយជំរកសត្វល្អិត និងជំងឺ ថែមទាំងជួយឱ្យដើមឈើមានលទ្ធភាពប្រមូលជាតិម្សៅ និងស្ករមកចិញ្ចឹមសរីរាង្គបានច្រើនជាងអាស្សូតវិញ ។ មែកដែលត្រូវកាត់គឺមែកបំពង់ (កុំកាត់មែកដែលចិញ្ចឹមទុកយកពកទងផ្កាចេញ) ។

**ខ. ប្រភេទនៃការកាត់តែងមែក**

- ការកាត់តែងមែកដើម្បីយកទ្រង់ទ្រាយដើម ត្រូវធ្វើនៅឆ្នាំដំបូង ពេលដើមនៅតូចៗត្រូវកាត់មែកខ្នែងដែលបែកចេញមកតាមខ្នែងឱ្យអស់ (ពីលើដីប្រមាណ ៣០-៤៥ សង្ទីម៉ែត្រ) ដើម្បីឱ្យគល់ស្រឡះ និងងាយស្រួលក្នុងការធ្វើស្មៅដាក់ជី
- កាត់តែងមែកដើម្បីត្រៀមឱ្យដើមឈើចេញផ្លែទៀងទាត់

ដើមឈើដែលលូតលាស់មានស្លឹក និងមែកច្រើនពេក នោះវាមិនអាចចេញផ្កា ផ្លែទេ ព្រោះវាត្រូវទទួលធាតុអាស្សូតច្រើន។ នៅពេលចេញផ្កាដើមឈើត្រូវមានអាហារ ពូកប៉ូតាស្យូម គ្រប់គ្រាន់ជាមុនសិន ដូច្នេះត្រូវកាត់មែកស្លឹកចេញខ្លះដើម្បីបង្គ្រប់សារធាតុចិញ្ចឹមក្នុងកំឡុងពេលចេញផ្កា។

## ការកាត់តែងមែកសំរាប់ឈើហូបផ្លែ




ការកាត់ត្រឹមត្រូវរាងបញ្ឆិតពីលើពកផ្កែកបន្តិច




កាត់លើកទី ១ ធ្វើឡើងពីក្រោមមែក




កាត់លើកទី ២ ធ្វើឡើងពីខាងលើមែក

ចំណាំ កាត់ក្រោមមែកជៀសវាងការរហែកសំបក ឬសាច់




កាត់លើកទី ៣ និងចុងក្រោយត្រូវធ្វើគៀកដើមប៉ុន្តែត្រឹមមែកងាយស្រួលក្នុងការយកចេញ ព្រោះជាកំណាត់ឈើខ្លីស្រាល

# ទ្រង់ទ្រាយដើមឈើដែលត្រូវធ្វើការកាត់តែង




ដើមត្របែក



ដើមចេក



ដើមស្វាយ

# ជំពូក ២
# ការបំបែកពូជ

ពូជជាកត្តាសំខាន់មួយក្នុងបណ្តាកត្តាផ្សេងៗនៃដំណាំឈើហូបផ្លែ។ ពូជអាចធ្វើឱ្យការដុះលូតលាស់ និងទិន្នផលខ្ពស់គុណភាពល្អ។ ជាទូទៅដើមឈើហូបផ្លែ អាចបំបែកពូជដាំបានតាមរយៈ ផ្លែ គ្រាប់ កូន និងមែក។ ការបំបែក ឬពង្រីកពូជមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទដំណាំ។

## ២.១ ការដាំឬពង្រីកពូជដោយផ្លែ



ការពង្រីកពូជ ឬ ដាំដោយផ្លែ មានលក្ខណៈងាយដោយគ្រាន់តែជ្រើសរើសផ្លែ ដែលមានសុខភាពល្អ និងគុណភាពល្អយកទៅបណ្តុះឱ្យដុះ រួចយកទៅដាំ ឧ. ដូចជា ដូង ស្លា ។ល។

## ២.២ ការដាំឬពង្រីកពូជដោយគ្រាប់



ការដាំដោយគ្រាប់ក៏ ដូចជាការដាំដោយផ្លែដែរ ព្រោះគ្រាប់បានមកពីផ្លែ។ យើងជ្រើសរើសយកផ្លែ មានសុខភាពល្អគ្មានរោគ ហើយពុះយកគ្រាប់លាងទឹកឱ្យស្អាត ហាលឱ្យស្ងួតក្នុងម្លប់ រួចជ្រើសរើសយកគ្រាប់ដែលមានសុខភាពល្អយកមកបណ្តុះដាំ នៅក្នុងកូនថង់តម្រៀបដាក់នៅក្នុងថ្នាល ដូចជា ទៀប ល្ហុង ល្មុត មៀន ។ល។

## ២.៣ ការដាំថ្នមជ្រើកពូជដោយកូន

ការដាំដោយកូន ក៏មានលក្ខណៈងាយស្រួលដែរ ដោយគ្រាន់តែជីកបំបែកយកកូន ដែលថ្លោស មានសុខភាពល្អ ពីដើមមេ យកទៅដាំតែម្តង ដូចជា ចេក ម្នាស់ ។



## ២.៤ ការបំបែកពូជដោយមែក

ការបំបែកពូជដោយមែកអាចធ្វើបានតាមវិធីច្រើនយ៉ាង ដូចជា វិធីសាកមែក ការបំបៅបន្តមែក និងការបំបៅតភ្នែក ។ល។ ចំពោះវិធីនិមួយៗអាស្រ័យលើការនិយមចូលចិត្តរបស់កសិករ ប៉ុន្តែកសិករនិយមប្រើបំផុតសំរាប់ដំណាំឈើហូបផ្លែដូចជា ក្រូច, ស្វាយ, មៀន, ខ្នុរ ត្របែកជាដើម ។ល។

### ២.៤.១ ការសាកមែក (Layering)

ការសាកជាការបំបែកពូជរុក្ខជាតិ ដោយធ្វើឱ្យមែករុក្ខជាតិកើតឫសក្នុងខណៈ ដែលនៅជាប់នឹងដើមមេ។ ពេលមែកចេញឫសល្អហើយក៏កាត់ទៅផ្សាំមុនដាំឬយកទៅដាំតែម្តងក៏បាន ។ ក្នុងការសាកមែកនេះត្រូវជ្រើសរើសយកមែកបញ្ឈរឬទ្រេតបន្តិច មានអាយុពី ៦ខែ ទៅ ១ឆ្នាំ និងគ្មានរោគ ។ ជ្រើសរើសមែកដែលមិនខ្ចី ហើយមិនចាស់ពេក ។



⊙ ជំហានទី១

ជ្រើសរើសមែកដែលមិនខ្ចីពេក មិនចាស់ពេក ចៀរក្រឡឹងដើម ជុំវិញមែកពីលើ និងពីក្រោមថ្នាំង។ សំរាប់ចន្លោះចៀរនោះប្រវែង ២-៣សង្ទីម៉ែត្ររួចឆ្កឹះកន្លែងចៀរហើយបកសំបកចេញ។

⊙ ជំហានទី២

ក្រោយពេលឆ្កឹះសំបកចេញហើយកោសពីលើចុះក្រោមថ្នមៗ ឱ្យអស់រំអិល និងសរសៃនាំទឹក សរសៃនាំសារធាតុចិញ្ចឹម ព្រោះបើទុកវាធ្វើឱ្យសាច់ថ្មីកើតឡើង ឫសនឹងមិនដុះ។



⊙ ជំហានទី៣

យកកំទេចស្រកីដូងម៉ដ្ឋ ដែលអាចជក់ទឹកបានយូរ មករុំពីលើស្នាមសាក (បើមិនមានស្រកីដូង អាចនឹងប្រើវត្ថុផ្សេងៗ ដែលមានលក្ខណៈស្រដៀងគ្នា គឺអាចប្រមូលបាននូវភាពសើម បានល្អ ជំនួសបាន)។



⊙ ជំហានទី៤

ក្រោយពីហ៊ុំដោយស្រកីដូងរួចហើយ ប្រើខ្សែចងផ្នែកលើក្រោមនៃស្រកីដូងឱ្យជាប់។ ក្រៅពីនោះត្រូវឧស្សាហ៍ពិនិត្យមើលសំណើមរបស់វា (ស្រកីដូងដែលហ៊ុំ) បើឃើញស្ងួតត្រូវស្រោចទឹកផង ។



**ឧទាហរណ៍នៃការសាកដើមក្រូចឆ្មារ**

ក្នុងការសាកដើមឈើ យើងត្រូវជ្រើសរើសដើមឈើ ដែលមានខ្លឹម ឬបណ្តូល។ គួរសាកក្នុងរដូវភ្លៀង ហើយមែកដែលសាកកុំឱ្យខ្ចី ឬចាស់ពេក។ ចំពោះឧបករណ៍ ដែលប្រើសំរាប់សាកមានៈ ស្រកីដូង ដែលផ្អាប់ទុកទាល់តែទន់ហើយដំឱ្យរីកស្មើសាច់ ស្លឹកចេកស្ងួត ខ្សែចំបើង កាំបិត ។ល។

⊙ ជំហានទី១

អង្កន់មែកឱ្យមានប្រវែងសមល្មម (២-៣ ស.ម) ។ ឆ្នូតអង្កន់ផ្នែកខាងលើគួរឱ្យនៅ ជាប់ផ្នែកខាងក្រោមនៃថ្នាំង ព្រោះវាជា បរិវេណដែលដុះឫសបានច្រើន។ កោស ឬបកសំបកជុំវិញត្រង់កន្លែង ដែលឆូតឱ្យអស់ ហើយឱ្យស្ងួត។ ការកោសត្រូវកោសពីលើចុះក្រោមដើម្បីការពារមុខកាត់នៃសំបកផ្នែកលើខូចរនេចរនូត។



⊙ ជំហានទី២

យកដីផ្អប់ៗជុំវិញកន្លែងដែលកោស (ដីមានជីជាតិ) ។ ហើយយកស្រកីដូងដែលត្រៀមទុកខ្ទប់ហ៊ុមកុំឱ្យជ្រុះដី រួចយកខ្សែចងផ្នែកលើនិងក្រោម ។



⊙ ជំហានទី៣

យកស្លឹកចេកស្ងួតរុំមួយជាន់ទៀត ដើម្បីរក្សាភាពជាប់ទឹក ហើយចងដោយខ្សែចំបើងជា ២កន្លែង ឱ្យណែន។ ក្រោយពីសាកបានរយៈពេល ២០-៣០ថ្ងៃ ឫសនឹងចាប់ផ្តើមចេញ។ ដូច្នេះ ប្រសិនយើងសាកនៅរដូវក្តៅត្រូវការស្រោចទឹកច្រើន នៅលើមែកដែលសាក។ តែបើយើងសាកនៅរដូវភ្លៀង មិនចាំបាច់ស្រោចទឹកទេ។



⊙ ជំហានទី៩



ក្រោយពីហ៊ុមដោយស្លឹកចេកស្រួចហើយ ប្រើខ្សែចងផ្នែកលើ និងក្រោម (ចងផ្នែកខាងចុង និងខាងគល់ឱ្យណែនជៀសវាងកុំឱ្យទឹកហួតឆាប់)។ ក្រោយពីនោះត្រូវឧស្សាហ៍ពិនិត្យមើលនូវសំណើម របស់វាបើស្ងួតត្រូវស្រោចទឹក។ រយៈពេល ១-២ ខែ ក្រោយពី ពេលសាកទើបឃើញឫសប្រែពណ៌ពី ស ទៅ ត្នោត ទើបអាច កាត់យកទៅផ្សាំសិន ឬដាំតែម្តង។

### ២.៤.២ ការភ្ជាប់មែក (Approach Grafting)

ការភ្ជាប់មែកជាការនាំយកដើមរុក្ខជាតិពីដើមមួយ ដែលមួយដើម១សុទ្ធតែមានឫស និងត្រូវនាំយកមក ផ្សារភ្ជាប់ជាសាច់តែមួយ លើដើមមួយទៀត ក្រោយពេលធ្វើការភ្ជាប់មែកពូជល្អ (ផល) ជាមួយដើមទំរហូតដល់ជាប់ គ្នាហើយទើបកាត់មែកភ្ជាប់ចេញពីដើមមេ។

⊙ ជំហានទី១



ត្រៀមដើមភ្ជាប់ ដែលនឹងនាំទៅភ្ជាប់ ដោយបិទបង្ហាប់ស្រកី ដូងចូលក្នុងថង់ប្លាស្ទិក ដើម្បីឱ្យមានទំងន់ស្រាល និងប្រមូលនូវ សំណើមទុកបានយូរ។

⊙ ជំហានទី២

យកដើមត្រូវភ្ជាប់ដែលត្រៀមទុក មកវាស់ភ្ជាប់ជាមួយមែកពូជល្អ (ផល) ដើម្បីមើលថា គួរនឹងចៀរដើមត នឹងមែកពូជបានយ៉ាងណា ។



⊙ ជំហានទី៣

យកដើមតមកកាត់ត្រួយចេញហើយប្រើកាំបិតចៀរបញ្ឆិតជាមាត់ឆ្លាម ។ ដូចគ្នាដែរចិតមែកពូជ ដើម្បីភ្ជាប់រួច ភ្ជាប់ចូលរកគ្នាឱ្យជិត ។



⊙ ជំហានទី៤

ប្រើប្លាស្ទិករុំដើមត ទប់ជាមួយមែកឱ្យណែន រយៈពេលប្រមាណ ២ខែទើបភ្ជាប់គ្នាជាសាច់មួយបានយ៉ាងជិត ។



២.៤.៣ ការតមែក (Grafting)

ការតមែកជាការបំបែកពូជ ដោយនាំយកមែកពូជដែលមានភ្នែកច្រើនជាងមួយ ទៅធ្វើការតភ្ជាប់មែកលើដើមទំរ ដើម្បីឱ្យបានពូជល្អតាមតម្រូវការ ដើមទំរនេះនឹងរីកចំរើន ជារុក្ខជាតិដើមតែមួយ ។ វិធីតមែកដែលបានផ្សាយមានច្រើនវិធីដូចជា ៖

**ក.ការតមែកបែបស្មៀតមែកពីចំហៀង**

⊙ ជំហានទី១

ចៀរដើមទំរផ្នែកចំហៀងបញ្ឆិតចុះក្រោមទៅឱ្យជ្រៅប្រមាណ ១ភាគ៣ នៃដើម ហើយនាំយកមែកដែលពូជល្អ ( ផល) មកចិតជាបញ្ឆិតរួចស្មៀតចូលទៅត្រង់ ។



⊙ ជំហានទី ២

ពេលស្ទៀតមែកពូជល្អ (ផល) ចូលជាមួយដើមទំរហើយ ត្រូវរុំដោយប្លាស្ទិកឱ្យណែន។



**ខ.ការតមែកបែបស្ទៀតចំសាច់ឈើ**

ការតមែកនេះ ជាទីពេញនិយមប្រើជាមួយ ការតត្រួយ ជាពិសេសដែលមានវិធីដូចតទៅនេះ :

⊙ ជំហានទី ១

ពុះដើមតបរិវេណពាក់កណ្តាលឱ្យជ្រៅល្មម ។



⊙ ជំហានទី២



យកមែកពូជល្អ (ផល) មកចិតផ្នែកចុងសងខាងរាងសំប៉ែត រួចសៀតចូលទាំង ២ ផ្នែកភ្ជាប់ជាមួយសំបករបស់ដើម ក្រោយពីនោះប្រើក្រមួនលាបបិទមាត់ប្រហោងឱ្យជិតការពារទឹកចូល ។

## ២.៤.៤ ការភ្ជាប់ភ្នែក (Bud Grafting)

ការភ្ជាប់ភ្នែកជាវិធីបំបែកពូជរុក្ខជាតិមួយផ្នែកទៀត ដោយនាំយកផែនភ្នែកពីមែកពូជល្អ (ផល) ទៅភ្ជាប់ជាមួយដើមទំរដើម្បីឱ្យបានពូជតាមតំរូវការ ហើយអាចលូតលាស់ជារុក្ខជាតិដើមជាមួយគ្នាបាន។

⊙ ជំហានទី១



ឆូតដើមជារូបអក្សរតេ (T) រួចហើយប្រើកាំបិតមួយផ្នែកផ្សេងដើម្បីបកសំបកចេញ។

⊙ ជំហានទី២

ជ្រើសរើសភ្នែក ដែលកំពុងលូតលាស់ល្អ ពីមែកពូជល្អ ដោយចៀរយកភ្នែកឱ្យជាប់សាច់ឈើមកផង តែយកសាច់ឈើចេញមុននឹងដាក់សៀតចូលក្នុងដើមទំរ ដែលបំរុងទុកជាស្រេច ។



⊙ ជំហានទី៣

យកផ្ទៃករបស់ភ្នែកដែលបានឆ្កឹះទុក ដែលយកសាច់ឈើចេញហើយ នោះទៅស៊កចូលទៅកន្លែង ដែលបើកសំបកទុកនៅដើមទំរ ។



ជំហាន់ទី៤

ពេលស៊ិកចូលរៀបរយ ហើយរុំដោយប្លាស្ទិកដើម្បីការពារទឹកចូលទុកចោល រយៈពេលប្រមាណ ១៥-២០ថ្ងៃ ភ្នែកនឹងរីកចំរើនភ្ជាប់ជាមួយដើម ទើបបើកប្លាស្ទិកដែលយើងរុំនោះចេញ។



# ជំពូក ៣
# បទពិសោធន៍ជាក់ស្តែងរបស់កសិករក្នុងការដាំឈើហូបផ្លែ

## ៣.១. បទពិសោធន៍ដាំចេកអំបូង

លោកពូ សយ ទិត្យ ជាកសិកររស់នៅភូមិការហែង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ គាត់មានបទពិសោធន៍ល្អមួយក្នុងការដាំដុះចេកអំបូង ហើយទទួលបានផលល្អ ដែលបទពិសោធន៍នេះ គាត់បានអនុវត្តន៍អស់រយៈពេលប្រាំឆ្នាំមកហើយ ។ លទ្ធផលដែលគាត់ទទួលបាននេះធ្វើអោយអ្នកដែលនៅជិតផ្ទះរបស់គាត់ និងកសិករផ្សេងដែលមកទស្សនកិច្ចសិក្សាមានការចាប់អារម្មណ៍ និងធ្វើការសាកសួរនូវព័ត៌មានពីគាត់ដើម្បីយកទៅអនុវត្តន៍តាម ដូចនេះ ខ្ញុំសូមលើកយកបទពិសោធន៍ដាំចេកអំបូងរបស់គាត់មកបង្ហាញជូនដូចខាងក្រោម :

### ១.បច្ចេកទេសនៃការដាំចេកអំបូង

#### ក. ការជ្រើសរើសកូន

គាត់ជ្រើសរើសយកកូន ដែលដុះចេញពីដើមចាស់ ដែលមានអាយុចាប់ពី ១-២ ឆ្នាំ (យកកូនចេកណាដែលឡើងគល់ ឬ ហៅថាកំពឹងចេក) មានកំពស់ ០.៥-១ ម៉ែត្រ និងដុះស្លឹកចាប់ពី ២-៣ សន្លឹក។



កាប់កូនចេកចោលទុកតែ ១-២ដើម ក្នុង ១គុម្ព

#### ខ. ការរៀបចំរណ្តៅ និងការដាំ

- កាប់រណ្តៅទំហំ ១ម៉ែត្របួនជ្រុង និង ជំរៅ ៨តឹក ទុកគម្លាតពីរណ្តៅមួយ ទៅមួយចំងាយ ២ ម៉ែត្រ
- ដាក់សំរាមដូចជាស្លឹកឈើងាប់ៗ សំរាមពុកផុយ ១-២ បង្គី (ហាមយកស្លឹកឈើស្រស់ទៅដាក់ក្នុងរណ្តៅ)
- យកកូនចេកដាក់ដាំក្នុងរណ្តៅ រួចកប់ដីអោយលិចគល់កូនចេក ដោយយកដីកំប៉ុស្តចំនួន ២ បង្គី លុបថែមពីលើជាការស្រេច។

#### គ. ការថែទាំ

- ស្រោចទឹកជាប្រចាំ នៅពេលចេកជិតធ្លាក់ត្រយូង
- ទុកត្រយ៉ូងចេកចេញឱ្យអស់ផ្លែ (មិនត្រូវកាច់ត្រយ៉ូងលឿនពេកទេ)
- ជះទឹកលើផ្លែចេក ២ដង ក្នុងមួយថ្ងៃ (ព្រឹក និងល្ងាច) ដើម្បីជួយជំរុញផ្លែចេកអោយឆាប់ រីកធំ
- នៅរដូវប្រាំងជីករណ្តៅធ្វើជារាងកំពែងនៅជុំវិញគល់ ដែលអាចដក់ទឹកបាននៅពេលស្រោចទឹក

- នៅពេលចេកដុះកូនចេញច្រើន គាត់រក្សាទុកតែ ១ ដើម ក្នុង ១ គុម្ព ដើម្បីឱ្យកូនចេកមានផ្លែថ្លោសល្អ ។

## ២.ការប្រមូលផល

- ដាំបានរយៈពេលពី ៥-៦ ខែ អាចប្រមូលផល លើកទី ១ បានគឺ ក្នុង ១ ស្ទង ពី ១១-១២ ស្និត ក្នុងមួយស្និត មានពី ២០ ទៅ ២៥ ផ្លែ (ក្នុងមួយដើម) បើគាត់ប្រៀបធៀបទៅពីមុនពេលដាំតាមរបៀបនេះគឺ វាទទួលបានផ្លែតិចជាង ពិសេស ផ្លែមិនសូវថ្លោសល្អទៀតផង
- ប្រមូលផលលើកទី ២ បន្ទាប់ពីរយៈពេល ៦ ខែ ទៀត ឬ យើងធ្វើការប្រមូលផលជាបន្តបន្ទាប់គ្នា
- ក្នុងចេកមួយស្ទង គាត់អាចលក់បានចាប់ពីតំលៃ ១២០០០ រៀល ទៅ ១៥០០០ រៀល ។

## ៣.ចំណាប់អារម្មណ៍

តាមរយៈការដាំចេកនេះធ្វើអោយគាត់ធូរកំលាំងច្រើនជាងការដាំដុះដំណាំផ្សេងៗទៀតនៅក្នុងផ្ទះរបស់គាត់ព្រោះដំណាំនេះមិនចំណាយពេលច្រើនទៅលើការថែទាំប៉ុន្មានទេ និងអាចផ្តល់ផលរហូត ហើយពិសេសមានតំលៃខ្ពស់នៅទីផ្សារទៀតផង ។ ដូចនេះប្រសិនបើបងប្អូនកសិករមិនសូវមានពេលវេលាគ្រប់គ្រាន់អាចជ្រើសរើសយកដំណាំចេកមកដាំបាន ។



ទិដ្ឋភាពនៅពេលចេកធ្លាក់ស្ទង

សរុបមក បច្ចេកទេសដាំចេកអំបូងសំខាន់ៗមានៈ

- កាប់រណ្តៅជ្រៅដាក់ជីធម្មជាតិពុកផុយ
- ដាំគម្លាតគុម្ពឆ្ងាយពីគ្នា (២ ម៉ែត្រ) ដើម្បីឱ្យមានពន្លឺចូលគ្រប់គ្រាន់កប់ចេកដាំឱ្យលិចគល់
- នៅរដូវប្រាំងជីករណ្តៅជុំវិញគុម្ពចេករាងជាកំពែង ដើម្បីឱ្យដក់ទឹក
- ស្រោចទឹកជាប្រចាំនៅពេលចេកធ្លាក់ត្រយូង
- រក្សាទុកកូនចេកតែ ១ ដើម ក្នុង ១ គុម្ព ដើម្បីឱ្យចេកមានផ្លែថ្លោសល្អ
- ជះទឹកលើផ្លែចេក ១ ថ្ងៃ ២ ដង ដើម្បីឱ្យផ្លែឆាប់រីកធំ ។

## ៣.២. បទពិសោធន៍ដាំស្វាយកែវរមៀត

<u>បទពិសោធន៍ទី១</u>

បងប្រុស អឿន សំអាង មានអាយុ ២៩ ឆ្នាំ ជាកសិករសរស់នៅភូមិស្វាយមាស ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។ គាត់មានបទពិសោធន៍ក្នុងការដាំស្វាយកែវរមៀត ដែលបទពិសោធន៍នេះគាត់បានស្វែងយល់ពីអ្នកជិតខាង និងតាមរយៈការអានឯកសារផ្សេងៗ.

ខាងក្រោមនេះជាបទពិសោធន៍របស់គាត់ផ្ទាល់ ហើយ សូមលើកយកមកបង្ហាញជូនដូចខាងក្រោម៖



ទិដ្ឋភាពដើមស្វាយកែវរមៀតនៅពេលចេញផ្លែ

### ក. ការជ្រើសរើសទីតាំង និងពូជ

គាត់ជ្រើសរើសទីតាំងដាំនៅតាមភ្លឺស្រែ ព្រោះជាដីចួរសំបូរដោយជីជាតិ និងជិតប្រភពទឹកដែលអាចឱ្យស្វាយមានការលូតលាស់លឿន ។

### ខ. ការរៀបចំរណ្ដៅ និងការដាក់ជី

ក្នុងការដាំ គាត់បានជីករណ្ដៅជំរៅ ៧ តឹក និងទំហំ ៧តឹក ៤ជ្រុង ។ បន្ទាប់មកទុករណ្ដៅហាលចោលរយៈពេលពី ២ ទៅ ៣ថ្ងៃ ដើម្បីសំលាប់មេរោគ ។ ចំពោះការដាក់ជី គាត់រៀបជាស្រទាប់ដូចខាងក្រោម៖




<u>ស្រទាប់ទី ៦</u> ដាក់អាចម៍គោម៉ដ្ឋៗលាយជាមួយដីធម្មតាកំរាស់ចំនួន ២.៥ តឹក ។

<u>ស្រទាប់ទី ៥</u> ដាក់ចំបើងលាយជាមួយស្លឹកឈើ អង្កាម សំដីស្រូវកំរាស់ចំនួន ១ តឹក និងរោយកំបោរចំនួន ១ស្លាបព្រាដើម្បីសំលាប់កណ្ដៀរ និងធ្វើឱ្យជីឆាប់រលួយចូលគ្នា

<u>ស្រទាប់ទី ៤</u> ដាក់ដីធម្មតា (ដីស្រទាប់លើ) ចំនួន ១ តឹក

<u>ស្រទាប់ទី ៣</u> ដាក់អាចម៍គោក្រៀមដែលពុកផុយកំរាស់ចំនួន ១ តឹក

<u>ស្រទាប់ទី ២</u> ដាក់កំទេចកំទីចំបើងមិនទាន់រលួយកំរាស់ចំនួន ១ តឹក

<u>ស្រទាប់ទី ១</u> នៅបាតរណ្ដៅដាក់កំបោរចំនួន ២ ស្លាបព្រា ឬ ដាក់ប្រេងម៉ាស៊ីនដើម្បីការពារកណ្ដៀរ។

បន្ទាប់ពីដាក់ជីរៀបជាស្រទាប់រួចហើយ ទុករយៈពេល ១៥ ថ្ងៃ ដើម្បីឱ្យជីពុកផុយ ទើបយកកូនមកដាក់ដាំ ។ ការដាំកូនចាប់ផ្តើមដាំនៅដើមរដូវវស្សា ឬ នៅខែកក្កដា ព្រោះវាធ្វើឱ្យដំណាំលូតលាស់ល្អ និងមិនសូវពិបាកក្នុងការស្រោចទឹក ។

## គ. ការថែទាំ

នៅឆ្នាំទី ១ គាត់បានកាប់ជីជុំវិញដើម ដោយមានចំងាយពីគល់ប្រហែលជា ១ តឹក បន្ទាប់មកយកអាចម៍គោក្រៀមមកដាក់ក្នុងរណ្តៅ (ដោយមិនកំណត់) ហើយស្រោចទឹករយៈពេល ៣ ទៅ ៥ ថ្ងៃម្តង (នៅរដូវប្រាំង) ។ នៅឆ្នាំទី ២ ទី ៣ គាត់មិនបានធ្វើការដាក់ជីបំប៉នបន្ថែមទៀតទេដោយគាត់គិតថាឫសរបស់វាអាចមាន លទ្ធភាពគ្រប់គ្រាន់ក្នុងការស្រូបយកជីជាតិបាន ។ ចំណែកឯបញ្ហាសត្វល្អិតវិញ តាមការសង្កេតកន្លងមក មិនឃើញមានការបំផ្លាញទេ ហើយសូម្បីតែសត្វក្រាក៏គ្មានដែរ ។

## ឃ. ការប្រមូលផល



ក្រោយពេលដាំអស់រយៈពេល ៣ ឆ្នាំ ស្វាយចាប់ផ្តើមផ្លែ ។ ប៉ុន្តែការផ្លែនៅលើកទី ១ នេះ ទិន្នផលដែលទទួលបានមានកំរិតទាបនៅឡើយ ជាមធ្យម ៥-១០ ផ្លែ ក្នុងមួយដើម ។ ឆ្នាំទី ៤ និងឆ្នាំ ទី ៥ ស្វាយបានឱ្យផល ២ ដងក្នុងមួយឆ្នាំ ប៉ុន្តែទិន្នផលដែលជាក់លាក់នោះ គឺគាត់មិនបានកត់ទុកទេ បើគិតជាមធ្យមបានប្រហែលជា ១ ទៅ ២បួន ក្នុង ១ ដើម (១ បួន ស្មើនឹង ៥០ ផ្លែ) ក្នុងមួយរដូវ ។ ប៉ុន្តែនៅរដូវទី ២ ឬ រដូវដែលប្រជាជន ខ្មែរតែងតែហៅថាផ្លែខុសរដូវនោះគឺ ទិន្នផលតិចជាងរដូវធម្មតា ។

ចំពោះប្រាក់ចំណូលដែលគាត់ទទួលបានក្នុងមួយរដូវជាមធ្យមបានត្រឹមតែពី ១០ ទៅ ២០ម៉ឺនរៀលតែប៉ុណ្ណោះ ព្រោះភាគច្រើនគឺ គាត់ចែកជូន បងប្អូន និងញាតិមិត្តជិតខាងច្រើនជាងការលក់ដូរ ។

ជាសរុបចំនុចដែលធ្វើឱ្យស្វាយលូតលាស់ល្អ និងទទួលបានទិន្នផលខ្ពស់មានៈ

- ដាក់ជីទ្រាប់បាតឱ្យបានច្រើន (ជីធម្មជាតិរៀបជាស្រទាប់)
- ដាំក្បែរប្រភពទឹក (ងាយស្រួលស្រោចទឹក)
- ដាក់ជីបំប៉នឱ្យបានច្រើននៅឆ្នាំទី ១
- ខិតស្ងាហ៊ាចៀរដើម ដើម្បីឱ្យឆាប់រីកដើម និងស្មុះធំលឿន
- ដាំកណ្តាលវាល ដើម្បីឱ្យស្វាយទទួលបានពន្លឺគ្រប់គ្រាន់ ។

បទពិសោធន៍ទី២

ចំពោះអ្នកមីង វ៉ាន់ យ៉េត ដែលរស់នៅស្រុកបន្ទាយស្រី ភូមិបន្ទាយស្រី ឃុំខ្នារសណ្ដាយ ខេត្តសៀមរាប ក៏មានបទពិសោធន៍ដាំស្វាយកែវរមៀតបានល្អដែរ ។

ការដាំស្វាយកែវរមៀតនេះអ្នកមីងបានចេះពីដូនតារបស់គាត់ៗមកដោយគាត់មិននិយមប្រើជីគីមី និងថ្នាំពុលអ្វីឡើយ ។ គាត់បានដាំស្វាយ ១៥០ ដើម ដែលបច្ចេកទេសដាំដុះរបស់គាត់បង្ហាញជូនដូចខាងក្រោម ៖

**ក. ការរៀបចំរណ្ដៅដាំ**

គាត់ចាប់ផ្ដើម កាប់រណ្ដៅដាំនៅដើមរដូវភ្លៀងក្នុងកំឡុងខែ ឧសភា-មិថុនា ។ រណ្ដៅមានទំហំ ១ ម៉ែត្របួនជ្រុង និងជំរៅកន្លះម៉ែត្រ ។ នៅបាតរណ្ដៅនិមួយៗ គាត់បានដាក់ស្លឹកឈើស្រស់ដូចជា ទន្រ្ទាងខែត្រ ជាន់ឱ្យណែនកំរាស់ ៣ តឹក អាចម៍គោស្ងួត ២ តឹក ដី ១ តឹក នៅខាងលើ ។ ក្រោយពីដាក់ជីហើយ ទុកចោលរយៈពេល១អាទិត្យ ដើម្បីឱ្យស្លឹកទន្រ្ទាងខែត្ររលួយ ។ បន្ទាប់មកជ្រុំជ្រោយដីក្នុងរណ្ដៅឱ្យសព្វ ទើបដាក់កូនស្វាយដាំ ។ ចំងាយពីរណ្ដៅមួយទៅមួយ ៥ម៉ែត្រ ។



ដាក់ស្លឹកឈើងាប់ៗគ្របគល់ស្វាយ

**ខ. ការដាំ**

កូនស្វាយដែលគាត់បណ្ដុះទុកមានអាយុ ៦ ទៅ ៧ខែ ។ គាត់បានយកកូនស្វាយទៅកប់ដាំក្នុងរណ្ដៅ ដែលបានត្រៀមទុក ។ ក្រោយពីដាំហើយ ស្រោចទឹកឱ្យជោគ បន្ទាប់មកយកកំទេចកំទីស្លឹកឈើស្ងួត គ្របគល់ស្វាយកុំឱ្យហួតសំណើម ។

**គ. ការថែទាំ**



ក្រោយពីដាំហើយ គាត់ចាប់ផ្ដើមស្រោចទឹក ១ដង ក្នុង ១ថ្ងៃ រហូតដល់ស្វាយលាស់ត្រួយថ្មី ទើបគាត់បន្ថយការស្រោចទឹកនៅ ១ អាទិត្យម្ដង ។ នៅពេលស្វាយអាយុបាន ១-២ឆ្នាំ គាត់ជីកចង្អូរជារង្វង់នៅជុំវិញដើមចំងាយពីដើមប្រហែល ១-១.៥ម៉ែត្រ ។ ជំរៅចង្អូរ ២តឹករួចដាក់ស្លឹកឈើស្រស់ និងអាចម៍គោពីលើរួចលប់ដី និងស្រោចទឹក ។ ក្រៅពីការដាក់ជីស្រោចទឹក គាត់បានជំរះស្មៅ នៅក្បែរគល់និងនៅចន្លោះរង ។ ការបន្ថែមជីធ្វើឡើងរៀងរាល់ឆ្នាំដោយ ជីកចង្អូរនៅជុំវិញដើម ហើយដាក់ជីនៅក្នុងចង្អូរនោះ ។

### ឃ. ការប្រមូលផល



ក្រោយពីដាំបានរយៈពេល ៣ ឆ្នាំ ស្វាយមានផ្លែ ។ គាត់ចាប់ប្រមូលផលបាន ២ដង ក្នុង ១ឆ្នាំ។ នៅលើផ្ទៃដី ០.៥ ហិកតា ដាំបាន ១៥០ដើម និងប្រមូលផលបាន ១,២០០ គីឡូក្រាម នៅឆ្នាំដំបូង ។

ចំពោះការលក់ដូរវិញ គាត់លក់បាន ១៥០០ រៀលក្នុង ១គីឡូក្រាម សរុបនៅឆ្នាំដំបូង គាត់រកចំណូលបាន ១,៨០០,០០០ រៀល ។ ចំណាយអស់ ៤៥០,០០០ រៀល លើការជីករណ្ដៅទិញពូជបន្ថែម ។ល។ សរុបចំណេញដុលនៅឆ្នាំដំបូង គាត់ទទួលបាន ១,៣៥០,០០០ រៀល ។

### ង. វិធីកែច្នៃធ្វើផែនស្វាយ

ចំពោះស្វាយដែលទុំជោរលក់មិនអស់ គាត់បានយកទៅធ្វើផែនស្វាយដោយច្របាច់យកសាច់ ទៅដាំកូរឱ្យដាច់ទឹក បន្ទាប់មកយកទៅវាសលើកន្ទេលស្លឹកត្នោត រួចហាលឱ្យស្ងួតជាកាស្រេច។ ផែនស្វាយនេះ គាត់ធ្វើសម្រាប់បរិភោគក្នុងគ្រួសារ ។

សរុបមកបច្ចេកទេសសំខាន់ៗក្នុងការដាំស្វាយកែវរមៀតមានៈ

- កាប់រណ្ដៅដាំដោយមានទំហំ ១ ម៉ែត្របួនជ្រុង ជំរៅកន្លះម៉ែត្រ ចំងាយពីគ្នា ៥ ម៉ែត្រ
- ដាក់ជីធម្មជាតិទ្រាប់បាតរណ្ដៅ និងទុកឱ្យជីស្លឹកឈើស្រស់រលួយ ទើបដាក់កូនដាំ
- ថែទាំគ្របគល់ស្វាយ និងស្រោចទឹកធ្វើស្មៅក្រោយពីដាំហើយ
- យកស្លឹកឈើងាប់គ្របគល់ស្វាយ
- ដាក់ជីបំប៉ននៅជុំវិញដើម ដោយជីកជាចង្អូរចំងាយ ១-១.៥ ម៉ែត្រ ពីដើម
- ការដាក់ជីបំប៉នធ្វើឡើងនៅពេលស្វាយមានអាយុ ២ ឆ្នាំឡើងទៅ ក្រោយពីដាំ និងដាក់រយៈពេល១ឆ្នាំម្ដង។

### ៣.៣. បទពិសោធន៍ដាំល្ហុងឱ្យបានផ្លែច្រើន



អ្នកមីង សេង មួយហៀក រស់នៅភូមិព្រៃកអុងប៉ាវ ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្តាល។ គាត់មានបទពិសោធន៍ដាំល្ហុងអស់រយៈពេល ១០ ឆ្នាំមកហើយនៅលើដី ១៣អារ។ បទពិសោធន៍នេះជាគំនិតច្នៃប្រឌិតរបស់គាត់ផ្ទាល់។ ក្នុងមួយរដូវប្រមូលផលម្តងៗ គាត់បេះបានផ្លែសរុបប្រមាណ ១០តោន ហើយទទួលប្រាក់ចំណេញដុលប្រមាណ ២លានរៀល។

#### ក. ការជ្រើសរើសពូជនិងការត្រៀមពូជដាំ

ល្ហុងដែលគាត់ដាំ ជាពូជដែលជ្រើសរើស និងរក្សាទុកដោយខ្លួនឯង ។ ចំពោះលក្ខណៈពូជដែលគាត់ជ្រើសរើសមានផ្លែធំវែង ផ្លែច្រើនមិនដាច់ ដើមមានសុខភាពល្អ ។ នៅពេលដែលផ្លែទុំល្អ គាត់ពុះយកគ្រាប់ចេញពីផ្លែទៅលាងទឹកឱ្យជ្រះរំអិល រួចយកទៅហាល ឬ សំដិលរហូតស្ងួត (២-៣ ថ្ងៃ) ទើបយកទៅច្រកកែវទុក ។

#### ខ. ការបណ្តុះកូន

គាត់បានយកគ្រាប់ទៅបណ្តុះ មុននឹងយកទៅដាក់ដាំក្នុងចំការ ។ គាត់យកដីដែលមានជីជាតិច្រកចូលក្នុងថង់ប្លាស្ទិកខ្មៅដែលត្រៀមរួចជាស្រេច បន្ទាប់មកយកគ្រាប់ទៅត្រាំទឹករយៈពេល ៣ ថ្ងៃ និងផ្អាប់ទុករយៈពេល ៧ ថ្ងៃ (ឱ្យដុះពន្លកសៗ) ទើបយកទៅដាក់ដាំនៅក្នុងថង់ពី ៣-៤ គ្រាប់ ក្នុង ១ ថង់ ។ ក្រោយពីដាក់គ្រាប់បណ្តុះហើយ គាត់ស្រោចទឹកឱ្យជោគរៀងរាល់ថ្ងៃ ដើម្បីឱ្យកូនល្ហុងលូតលាស់ល្អ ។ ចំពោះថ្នាលបណ្តុះកូន គាត់បានប្រក់រោងសំណាញ់ដើម្បីកុំឱ្យកូនល្ហុងត្រូវពន្លឺខ្លាំងពេក ។

#### គ. ការរៀបចំដីដាំ

ក្នុងការរៀបចំដីដាំ គាត់ភ្ជួរហាលដី ៤-៥ លើកដោយចន្លោះពីមួយលើកទៅមួយលើកមានរយៈពេល ១០ថ្ងៃ។ នៅពេលភ្ជួរលើកទី ១ គាត់បានដាក់ជីលាមកសត្វពុកផុយ ១.៥ ទៅ ២ តោន ភ្ជួរលុបលើផ្ទៃដី ១៣ អារ។ ក្រោយពីភ្ជួររាស់ហាលដីរួច គាត់លើកជារងដែលមានទទឹង ១.៥ ម៉ែត្រ បណ្តោយទៅតាមស្ថានភាពដី ។ នៅលើរង គាត់ជីករណ្តៅជាជួររណ្តៅនិមួយៗទំហំ ៣ តឹកបួនជ្រុង និងជំរៅ ៣តឹក ដោយទុកចន្លោះពីរណ្តៅមួយទៅមួយ ២.៥ម៉ែត្រ។ នៅក្នុងរណ្តៅនិមួយៗ គាត់ដាក់ជីលាមកសត្វពុកផុយច្របល់ជាមួយដីឱ្យសព្វ ។

## ឃ. ការដាំ

គាត់ចាប់ផ្តើមយកកូនល្ហុងទៅដាំនៅចុងខែមេសា ឬ ដើមខែឧសភា ដែលជាដើមរដូវវស្សា ដើម្បីកាត់បន្ថយការស្រោចទឹក។ កូនល្ហុងដែលគាត់យកមកដាំមានអាយុ ៤៥ ថ្ងៃ គាត់បានហែកថង់ចេញ រួចដាក់ក្នុងរណ្តៅ បន្ទាប់មកយកដីនៅមាត់រណ្តៅលុបសង្កត់ឱ្យណែន រួចយកកំទេចចំបើងគ្របជុំវិញគល់ និងស្រោចទឹកឱ្យជោគ ។ ក្នុងមួយរណ្តៅដាំមួយដើម ដោយជ្រើសរើសយកតែកូនល្ហុងដែលមានសុខភាពល្អ ។

## ង. ការថែទាំ

នៅពេលល្ហុងនៅតូច គាត់ស្រោចទឹក ១ ថ្ងៃម្តង ដោយប្រើទុយោបាញ់នៅលើស្លឹករហូតដល់ល្ហុងធំចេញផ្កា គាត់បញ្ចូលទឹកនៅតាមចន្លោះរង ៣ ថ្ងៃម្តង ឯយ៉ាងណាកុំឱ្យដីស្ងួតពេក ឬ សើមពេក ។ ក្រៅពីការស្រោចទឹក គាត់ឧស្សាហ៍ពូនគល់គឺនៅពេលដែលសង្កេតឃើញឫសល្ហុងមួយចំនួនដុះលើផ្ទៃដី និងក្រោយការប្រមូលផលលើកទី ២ ។ ល្ហុងជាដំណាំដែលត្រូវការពន្លឺថ្ងៃ ដូច្នេះគាត់បានកាច់មែកងាប់ៗនៅក្បែរគល់ប្រមូលចោល និងធ្វើស្មៅក្បែរគល់ ដើម្បីកុំឱ្យមានភាពស៊ុបទ្រុបឱ្យពន្លឺចាំងចូលគ្រប់គ្រាន់ ។ អ្នកមីងបានប្រើជីកែងចំនួន ៥ គីឡូក្រាម សម្រាប់បំប៉នដោយដាក់នៅក្បែរគល់មួយរណ្តៅបន្តិចៗ ។

ក្នុងការដាំល្ហុងនេះ គាត់តែងជួបប្រទះនូវសត្វល្អិត និងជំងឺមួយចំនួនដូចជា ជំងឺរលួយគល់ ធ្វើឱ្យស្លឹកស្រពោន រលួយឫស និងគល់ត្រឹមស្មើដីតែម្តង ជំងឺពុកឫសកែវ ធ្វើឱ្យស្លឹកឡើងលឿង និងបញ្ឈប់ការចេញផ្លែ ជំងឺឆ្កួតត្រួយ ធ្វើឱ្យ ត្រួយរួញ ហើយផ្អាកការចេញផ្លែ ។

ចំពោះវិធានការណ៍កំចាត់ បើល្ហុងនៅតូច គាត់ដកដើមចោល ឬ កាច់ស្លឹក ឬ ត្រួយដែលកើតជំងឺចោល ។ ចំពោះសត្វល្អិតមានក្រារោមផ្លែ ដែលធ្វើឱ្យផ្លែមិនសូវលូតលាស់ ហើយគ្មានរសជាតិ ។ ករណីសត្វក្រារោមផ្លែ គាត់មិនទាន់មានវិធានការណ៍កំចាត់ទេ ប៉ុន្តែវាកើតមានតិចតួចប៉ុណ្ណោះក្នុងចំការរបស់គាត់ ។

## ច. ការប្រមូលផល

ក្រោយពេលដាំបានរយៈពេល ៩ខែ គាត់ប្រមូលផលផ្លែល្ហុងចាស់លក់។ ការបេះធ្វើឡើងបន្តបន្ទាប់ក្នុងរយៈពេល ៦ខែ ទៅ ១ឆ្នាំ ក្រោយពីបេះ លើកទី ១ រហូតដល់ផ្លែខ្សោយ ទើបគាត់កាប់ដើម ចាស់ចោល និងដាំថ្មីឡើងវិញ។ តាមការប៉ាន់ស្មាន របស់គាត់ ជាសរុបគាត់បេះលក់បានប្រមាណ ១២ តោន (ល្ហុងខ្ចី) ។ ហើយបើទូទាត់លើការចំណាយ គាត់ទទួលបានចំណូលសុទ្ធ ២-៣ លានរៀល ។

ធ. ចំណាប់អារម្មណ៍របស់កសិករ

អ្នកមីងមានចំណាប់អារម្មណ៍ថា គាត់ពេញចិត្តនឹងទិន្នផលដែលគាត់ទទួលបាន។ ការដាំល្ហុងចំណាយពេលថែទាំតិចជាងការដាំបន្លែ រីឯផលដែលបានមកងាយស្រួលលក់ ហើយគាត់សង្ឃឹមថា ទៅថ្ងៃមុខ គាត់នឹងអាចទទួលបាននូវបច្ចេកទេសថ្មីល្អៗ មកអនុវត្តលើចំការរបស់គាត់ ដើម្បីឱ្យទទួលផលកាន់តែខ្ពស់ ។

សរុបមក បច្ចេកទេសសំខាន់ៗ ក្នុងការដាំល្ហុងមានៈ

- ជ្រើសរើសពូជដែលមានផ្លែធំវែង និងទុំល្អទុកធ្វើពូជ
- បណ្តុះគ្រាប់ និងថែទាំឱ្យកូនល្ហុងមានសុខភាពល្អ មុនយកទៅដាំក្នុងចំការ
- ភ្ជួរដីហាលច្រើនសារឱ្យដីធូរ និងស្ងួតទឹក
- រៀបចំរណ្តៅជាជួរនៅលើរង ដោយទុកចន្លោះឃ្លាតឱ្យមានពន្លឺគ្រប់គ្រាន់
- យកកូនល្ហុងទៅដាំនៅពេលមានអាយុ ៤៥ ថ្ងៃ ដោយជ្រើសរើសតែកូនមានសុខភាពល្អ
- ថែទាំគ្របគល់ ពូនគល់ បោចស្មៅ និងកាច់ស្លឹកងាប់ៗនៅខាងក្រោមចោលស្រោចទឹក ១ ថ្ងៃម្តង ពេលល្ហុងនៅតូច និង ៣ ថ្ងៃម្តង ពេលចេញផ្កា ។





## ៣.៤. បទពិសោធន៍ដាំក្រូចពោធិសាត់មានរសជាតិផ្អែម



ផ្លែក្រូចដែលដាំដោយប្រើជីធម្មជាតិ

លោកពូ មៀន ម៉េន រស់នៅភូមិអូតាប៉ោង ស្រុកបាកាន ខេត្តពោធិសាត់។ គាត់មានបទពិសោធន៍ដាំក្រូចពោធិសាត់រយៈពេល ៦ឆ្នាំមកហើយ។ បច្ចេកទេសនេះ គាត់ចេះដោយខ្លួនឯងតាមរយៈ ការដាំដុះដំណាំជាច្រើន នៅក្នុងចំការរបស់គាត់។ ក្រូចពោធិសាត់របស់គាត់ មានផ្លែរសជាតិផ្អែមឆ្ងាញ់ដោយសារគាត់បានប្រើលាមកប្រចៀវ ។

### ក. រដូវដាំដុះនិងការពង្រីកពូជដាំ

រដូវដាំដុះ ដែលល្អសម្រាប់ដំណាំក្រូចពោធិសាត់ គឺនៅដើមរដូវភ្លៀងព្រោះមិនពិបាកក្នុងការស្រោចទឹក។ ចំពោះពូជដាំ គឺគាត់បានទិញពីភូមិជិតខាង (ពូជបង្កាត់រវាងក្រូចឆ្មារ និងក្រូចពោធិសាត់) ប៉ុន្តែការពង្រីកពូជដាំក្រោយៗ គឺគាត់បានធ្វើការសាកដោយខ្លួនឯង ។



មែកក្រូចដែលបានធ្វើការសាកពង្រីកពូជ

ក្នុងការសាកពង្រីកពូជគាត់បានជ្រើសរើសយកមែកក្រូចប៉ុនម្រាមដៃ (មិនខ្ចីពេក និងមិនចាស់ពេក)។ បន្ទាប់មក គាត់លាក់សំបកលើក្រោម (សងខាង) ប្រវែង ២.៥ សង្ទីម៉ែត្រ (៤ ហ៊ុន) និងចំងាយ ១០-១៥ សង្ទីម៉ែត្រ ពីគល់មែក ។ បន្ទាប់មកកោសរំអិលចេញឱ្យស្អាត រុំដីមានជីជាតិជុំវិញ រួចយកថង់ប្លាស្ទិកចងរុំជុំវិញ និងចងកណ្តាល ។ ក្នុងការសាកពង្រីកពូជនេះ គាត់ចាប់ផ្តើមធ្វើនៅខែឧសភា ឬ មិថុនា ដែលជាដើមរដូវភ្លៀង ទើបមានសំណើមមែកក្រូច ដុះបានល្អ។ ក្រោយពីសាកបានរយៈពេល ៣ខែ ឫសដុះចេញពីកន្លែងសាកគាត់អាចកាត់យកទៅដាំនៅក្នុងរណ្តៅបាន ។

### ខ. ការរៀបចំរណ្តៅដាំ និងការដាំ

ចំពោះរណ្តៅដាំ គាត់បានរៀបចំដោយកាប់ទំហំ ០.៥ ម៉ែត្រ បួនជ្រុង និងជំរៅកន្លះម៉ែត្រ ។ គាត់កាប់ដាក់ដីស្រទាប់លើ ១ឡែកនិងស្រទាប់ក្រោមទុក ១ឡែក។ នៅក្នុងរណ្តៅនិមួយៗ គាត់បានដាក់លាមកប្រចៀវ ១គីឡូក្រាម

ជ្រុំច្របល់លាយជាមួយដីស្រទាប់លើទើបដាក់កូនដាំ ។ ចន្លោះគុម្ពដែលគាត់បានដាំពីដើមមួយទៅមួយ ៤.៥ ទៅ ៥ម៉ែត្រ ។ ក្រោយពីដាំ ហើយគាត់ស្រោចទឹកឱ្យជោគ រួចយកកំប្លោកស្ងួត ឬស្រស់គ្របជុំវិញគល់ ។ ការស្រោចទឹកធ្វើឡើង រយៈពេល ៤-៥ ថ្ងៃ ម្តងនៅពេលទើបដាំដំបូង ។

គ. ការថែទាំ



កូនក្រូចដែលបានកាប់ពីដើមសាកមកដាំ

ក្រោយពីដាក់ដាំកូនក្រូចក្នុងរណ្តៅ ហើយគាត់បានយកកូនឈើដោតជិតដើម រួចចងផ្តោបដើម ដើម្បីកុំឱ្យដួល រលំនៅពេលមានខ្យល់ ភ្លៀង ។ នៅជុំវិញគល់ គាត់បានធ្វើការជំរះ ស្មៅឱ្យស្អាត ដើម្បីកុំឱ្យសត្វល្អិតមកធ្វើជំរក និង ដណ្តើមជីជាតិពីដី ។

ចំពោះការស្រោចទឹកនៅពេលគ្មានភ្លៀង គាត់ស្រោច ៤-៥ ថ្ងៃម្តង (កូនក្រូចទើបដាំ) ដើមធំ គាត់ស្រោចទឹក ១៥ ថ្ងៃម្តងនៅរដូវក្តៅ ។ នៅរដូវវស្សាពុំមានធ្វើការស្រោចស្រពទេ ។ ក្នុងការដាក់ជីបំប៉ន គាត់ដាក់លើដើមក្រូចណា ដែលគាត់សង្កេតឃើញដើមមានការដុះលូតលាស់ខ្សោយ ។ គាត់កាប់រណ្តៅដោយមានចំងាយ ០.៥ ម៉ែត្រ ពីគល់ និងជំរៅ ០.៥ម៉ែត្រ ។ នៅក្នុងរណ្តៅនោះគាត់បានដាក់នូវលាមកសត្វគ្រប់ប្រភេទ មាន់ គោ និងប្រចៀវ ព្រមទាំងស្លឹកឈើងាប់ៗ ដើម្បីឱ្យរលួយក្លាយជាជី ។ ការដាក់ជីបំប៉នធ្វើឡើងតែ ១ ឬ ២ដងប៉ុណ្ណោះ ចាប់ពីដាំរហូតដល់ចេញផ្លែ ។





## ឃ. ការប្រមូលផល

ចំពោះពូជក្រូចដែលគាត់បានទិញគេ យកមកដាំមានរយៈពេល ៤-៥ ឆ្នាំ ទើបចេញផ្លែ ។ ចំពោះដើមដែលគាត់បានសាកពង្រីកពូជដាំខ្លួនឯង មានរយៈពេលតែ ១.៥ ឆ្នាំប៉ុណ្ណោះក្រូចចេញផ្លែ ។ ប៉ុន្តែផ្លែលើកទី ១ តិច និងទំហំផ្លែតូចៗ ។ ដើមក្រូចដែលគាត់បានដាំមានចំនួនប្រមាណ ២០០-៣០០ ដើមមានផ្លែបេះជាបន្ត ប៉ុន្តែគាត់ពុំទាន់បានលក់ដូរទេ ទុកគ្រាន់តែបរិភោគក្នុងគ្រួសារ និងចែកញាតិមិត្តជិតខាងប៉ុណ្ណោះ ។

## ង. ចំណាប់អារម្មណ៍

លោកពូមានប្រសាសន៍ថា នៅក្នុងចំការលោកពូមានដាំឈើហូបផ្លែជាច្រើនប្រភេទ ។ ប៉ុន្តែក្រូចពោធិសាត់គាត់បានដាំច្រើនជាងគេ បន្ទាប់មកល្មុត ទៀបបារាំង ម្នាស់ ។ល។ ដំណាំឈើហូបផ្លែរបស់គាត់មានរសជាតិផ្អែមឆ្ងាញ់ ព្រោះគាត់ប្រើតែជីធម្មជាតិ (លាមកប្រចៀវ លាមកគោ និងសំរាមស្លឹកឈើ) ។ តាមបទពិសោធន៍របស់គាត់ លាមកប្រចៀវធ្វើឱ្យផ្លែឈើមានរសជាតិផ្អែមឆ្ងាញ់ ។

សរុបមក បទពិសោធន៍សំខាន់ៗ ក្នុងការដាំក្រូចពោធិសាត់មានៈ

- ពង្រីកពូជដាំដោយសាកមែក ជ្រើសរើសមែកបំពង់មានម្សៅទៅសាក
- ចៀរកោសមែកឱ្យអស់រំអិលប្រវែង ២.៥ សង្ទីម៉ែត្រ រុំដីជុំវិញចងក្តោបថង់ប្លាស្ទីកពីក្រៅ
- កាប់មែកសាកដាំរយៈពេល ៣ ខែ ក្រោយពីសាក
- កាប់រណ្តៅដាំទំហំកន្លះម៉ែត្របួនជ្រុង និងជំរៅកន្លះម៉ែត្រ ចន្លោះពីដើមមួយទៅមួយ ៤.៥ ម៉ែត្រ
- ដាក់ជីអាចម៍ប្រចៀវ និងជីលាមកសត្វផ្សេងទៀតទ្រាប់បាត និងបំប៉ន
- ថែទាំជំរះស្មៅ ចងដើមជាប់បង្គោលកុំឱ្យរលំ ស្រោចទឹកនៅពេលរាំងគ្មានភ្លៀង
- ដាក់ជីបំប៉នដោយកាប់រណ្តៅនៅចំងាយ ០.៥ ម៉ែត្រ ពីគល់ជំរៅកន្លះម៉ែត្រ កប់នូវលាមកសត្វគ្រប់ប្រភេទ
- នៅពេលដាំកូនក្រូច កុំភ្លេចយកកូនឈើដោតជិតដើម ហើយចងផ្តោបដើម្បីកុំអោយកូនក្រូចរលំ ។

### ៣.៥. បទពិសោធន៍ដាំសាវម៉ាវ

សាវម៉ាវ ជាដំណាំឈើហូបផ្លែមួយប្រភេទដែលមានអាយុកាលយូរឆ្នាំ ។ គេសង្កេតឃើញកសិករនិយមដាំនៅខេត្តកំពត កំពង់សោម កំពង់ចាម (មេមត់) កោះកុង រតនៈគិរី មណ្ឌលគិរី ។ល។ យ៉ាងណាមិញ លោកពូ កាង លាទ រស់នៅភូមិមាអ៊ូ សង្កាត់បឹងតាព្រហ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មានបច្ចេកទេសដាំសាវម៉ាវបានយ៉ាងល្អ ដែលបទពិសោធន៍នេះជាគំនិតច្នៃប្រឌិតរបស់គាត់ផ្ទាល់ ។



ផ្លែសាវម៉ាវដែលលោកពូបានបេះពីចំការ

#### ក. ពេលវេលាដាំដុះ និងពូជ

ពេលវេលាដែលដាំដុះល្អសម្រាប់ដំណាំសាវម៉ាវ គឺនៅដើមរដូវវស្សា ដែលក្នុងពេលនេះដីមានសំណើម កាត់បន្ថយការស្រោចទឹក ។ ចំពោះពូជដែល គាត់យកមកដាំគឺជាពូជដែលមានសាច់ច្រើន រសជាតិផ្អែម សាច់មិនជាប់ជាមួយគ្រាប់ ផ្លែមានរោមវែង គឺជាពូជដែលនាំមកពីប្រទេសថៃ ។



ទិដ្ឋភាពនៃដើមសាវម៉ាវក្នុងចំការ

#### ខ. ការរៀបចំដី និងការដាំ

លោកពូបានដាំនៅតំបន់ដីព្រៃ ។ មុនដាំ គាត់បានឈូសឆាយដីសំអាតស្មៅ និងគាស់គល់ឈើ និងភ្ជួរឱ្យបាន ២-៣ សា ដើម្បីឱ្យដីផុសល្អ ។

ក្នុងការដាំ គាត់បានជីករណ្ដៅដែលមានទំហំកន្លះម៉ែត្រ ៤ ជ្រុង និងមានជំរៅកន្លះម៉ែត្រ ។ ក្នុង ១ រណ្ដៅ គាត់បានដាក់ជីលាមកគោពុកផុយចំនួន ៤ បង្គី និងទុកចន្លោះពីរណ្ដៅមួយទៅមួយ ៦ ម៉ែត្រ ។

ក្រោយពីកាប់រណ្ដៅរួច គាត់បានយកកូនសាវម៉ាវដែលបានទិញយកមកដាំក្នុងរណ្ដៅ រួចស្រោចទឹកឱ្យជោគ ។

## គ. ការថែទាំ

នៅពេលសាវម៉ាវនៅតូច គាត់ស្រោចទឹក ជាពិសេសពេលដែលគ្មានភ្លៀង (ស្រោច ១អាទិត្យម្តង) ។ នៅពេលសាវម៉ាវធំ គាត់ស្រោច ២អាទិត្យ ឬ ១ខែម្តង (នៅរដូវប្រាំង) ។

ការដាក់ជីធ្វើឡើងរយៈពេល ១ ឆ្នាំម្តង ឬ ២ ដង ។ នៅឆ្នាំទី ២ និងទី ៣ គាត់ដាក់ជីលាមកគោចំនួន ៤-៥ បង្គី ។ ការដាក់ជី គឺគាត់បានជីកចង្អូរជុំវិញដើមចំងាយពីគល់ ០.៥ ម៉ែត្រ បន្ទាប់មកលប់ដីគ្របចង្អូរឱ្យជិតវិញ ។ នៅចុងឆ្នាំ គាត់បានដាក់ជីដេអាប៉េ ក្នុងបរិមាណពី ៣-៥ ខាំ ក្នុង ១ រណ្តៅ ។ លុះចាប់ពីឆ្នាំទី ៤ ឡើងទៅ គាត់បានដាក់ជីលាមកសត្វចំនួន ៥-៦ បង្គី ។ ចំពោះវិធីនៃការដាក់ជីធ្វើដូចឆ្នាំទី ១ ដោយកាប់ចង្អូរជុំវិញដើម (ចំងាយ ១ ម៉ែត្រ ពីគល់) ។

នៅជុំវិញគល់ គាត់បានធ្វើស្មៅឱ្យស្អាត និងធ្វើការកាប់មែកណាដែលងាប់ និងដុះប្រជ្រៀតគ្នាខ្លាំងចោល ដើម្បីឱ្យពន្លឺចាំងចូលដល់គល់ និងកុំឱ្យកើតជាជម្រកសត្វល្អិត ។

## ឃ. ការប្រមូលផល

សាវម៉ាវចាប់ផ្តើមផ្តល់ផលពីអាយុ ៤-៦ ឆ្នាំ បន្ទាប់ពីដាំ ។ ប៉ុន្តែចំពោះដើមដែលបំឌ ផ្តល់ផលនៅអាយុ ២-៤ ឆ្នាំ ។ នៅពេលសាវម៉ាវចាប់ផ្តើមផ្លែដំបូង គាត់បេះចោល ព្រោះដើមសាវម៉ាវនៅតូច គាត់ចង់ទុកឱ្យសាវម៉ាវបន្តការលូតលាស់ដើមបន្តទៀត ។ នៅឆ្នាំទី ៥ គាត់ទុកផ្លែខ្លះ (ផ្លែណាដែលធំៗ) ។ លុះដល់ឆ្នាំទី ៦ ទើបគាត់ទុកផ្លែទាំងអស់ ។



ដើមសាវម៉ាវក្រោយពីការលះមែកអោយស្រឡះ

សរុបមក បច្ចេកទេសសំខាន់ៗ ក្នុងការដាំ សាវម៉ាវមានៈ

- ជ្រើសរើសពូជដាំឱ្យបានល្អ (ផ្លែមសាច់ក្រាស់ សាច់មិនជាប់គ្រាប់)
- ជីករណ្តៅដែលមានទំហំធំល្មម និងដាក់ជីលាមកសត្វទ្រាប់បាត
- ថែទាំស្រោចទឹកពេលកូននៅតូច និងនៅរដូវប្រាំង
- ដាក់ជីទៅតាមឆ្នាំ ជីលាមកសត្វ
- ជំរះស្មៅ និងកាត់មែកងាប់ និងមែកចង្អៀតដើម្បីឱ្យពន្លឺចូលដល់គល់
- បេះផ្លែលើកទី ១ ចោលដោយទុកឱ្យដើមសាវម៉ាវលូតលាស់ធំល្អ ។

ពីគ្នាដើម្បីឱ្យពន្លឺចាំងចូលបានគ្រប់គ្រាន់ ធ្វើឱ្យមៀនមានការលូតលាស់ និងផ្លែផ្កាល្អ។

### ឃ. ការថែទាំ



ផ្លែមៀននៅពេលប្រមូលផល

ចំពោះការថែទាំគាត់បានយកចិត្តទុកដាក់ក្នុងការស្រោចទឹក និងជ្រុំគល់ឱ្យដីធូរមានខ្យល់ចេញចូល។ ការស្រោចទឹក ធ្វើឡើងមួយថ្ងៃ ២ដង (ព្រឹក និងល្ងាច) គឺនៅពេលដែលកូនមៀននៅតូច។ នៅពេលដែលមៀនមាន អាយុ ២ឆ្នាំឡើងទៅគាត់បន្ថយការស្រោច ទឹកនៅសល់ ១ថ្ងៃ ម្តង ឬ ២-៤ថ្ងៃម្តងអាស្រ័យទៅតាមសភាពជាក់ស្តែង (មានភ្លៀង ឬគ្មានភ្លៀង)។ ព្រមជាមួយគ្នានេះដែរ គាត់ឧស្សាហ៍ជ្រុំគល់បំផុសដី កប់នូវកាកសំណល់រុក្ខជាតិ សំរាម ស្លឹកឈើ ឱ្យរលួយក្លាយជាដី។ ការជ្រុំគល់ធ្វើ ឡើងក្នុង ទៅរយៈពេល ៣-៤ខែម្តង។ ក្រៅពីការជ្រុំគល់គាត់ធ្វើការលះមែកខាងក្រោមចេញឱ្យស្រឡះ និងយកឈើទល់ដើមដែលមានសភាពទ្រេតកុំឱ្យដួល។ នៅពេលមៀនចេញផ្លែគាត់បានយកកន្ត្រកដែលធ្វើពីឬស្សីគ្របផ្លែ ការពារការបំផ្លាញរបស់សត្វជ្រើង។ នៅពេលមៀនជិតចេញផ្កា និងពេលចេញផ្កាគាត់ធ្វើការស្រោចទឹកឱ្យជោគ និងសើមជានិច្ចដើម្បីជួយឱ្យការចេញផ្កាបានច្រើន និងកាន់ផ្លែ។ រហូតដល់មៀនចេញផ្លែទើបបន្ថយការស្រោចទឹក។

### ង. ការប្រមូលផល



សាច់មៀន

យើងអាចប្រមូលផលមៀនបាន ក្រោយពីដាំរយៈពេល ៣ ឆ្នាំ ឬ ៥-៦ឆ្នាំ អាស្រ័យទៅតាមប្រភេទពូជ។ ប៉ុន្តែចំពោះប្រភេទពូជ ដែលអ៊ំស្រីបានដាំមានរយៈពេល ៣ ឆ្នាំ ហើយចេញផ្កានៅ ចន្លោះខែ ១២ ដល់ ខែ ២ ដែលគេហៅថា ពូជមៀនចន្លក់។

ក្នុងការបេះប្រមូលផល គាត់ប្រើជណ្តើរឡើងកាត់ (ប្រើកន្ត្រៃកាត់) ឬទំពក់ ព្រោះមិនបណ្តាលឱ្យមែក និងដើមមៀនទ្រេត ឬបាក់។ ក្នុង ១រដូវគាត់បេះប្រមូលផលផ្លែមៀនបានចំនួន ជាមធ្យម ៣០-៥០គីឡូក្រាម ក្នុង ១ដើម។ ក្នុងចំការដែល មាន ៧៥ដើម អាចប្រមូលផលបាន ១៥០០-២០០០គីឡូ- ក្រាម។ ចំពោះផ្លែមៀនមានទីផ្សារណាស់ឈ្មួញបានមកទិញ ដល់ទីកន្លែងក្នុងតំលៃជាមធ្យម ៥០០០ រៀល ក្នុង ១គីឡូក្រាម (មៀនយូហ៊ុត)។ ក្រោយពីប្រមូលផលហើយម្តងៗ គាត់ធ្វើការស្រោចទឹក និងកប់នៅកាកសំណល់រុក្ខជាតិដើម្បីឱ្យរលួយក្លាយទៅជាដី។

សរុបមកបច្ចេកទេសសំខាន់ៗ ក្នុងការដាំមៀនឱ្យបានផ្លែ ច្រើន និងគុណភាពឈ្ងុយឆ្ងាញ់របស់គាត់មាន ៖

- រើសប្រភេទពូជក្នុងស្រុកដែលមានគុណភាពល្អ
- ដាក់គ្រាប់បណ្តុះក្នុងដីដែលមានជីធម្មជាតិ កំប៉ុស្ត លាមកសត្វ ពុកផុយ
- កាប់រណ្តៅទំហំ ៤ តឹកបួនជ្រុង ជំរៅ ៤ តឹក ដាក់ជីលាមក សត្វ ១ បង្គីជ្រុំនៅបាតរណ្តៅ
- ក្រាលសំរាមស្លឹកឈើនៅជុំវិញគល់មៀន
- ស្រោចទឹក ១ ថ្ងៃ ២ ដង ក្រោយពីដាំ
- ឧស្សាហ៍ជ្រុំគល់កប់នូវកាកសំណល់រុក្ខជាតិធ្វើឱ្យដីធូរ
- ប្រមូលផលហើយត្រូវស្រោចទឹកបន្ថែមជីធម្មជាតិដើម្បីបង្កើនការដាំដុះលូតលាស់នៅរដូវក្រោយ
- ធ្វើការលះមែកខាងក្រោមឱ្យស្រឡះ ដើម្បីឱ្យពន្លឺចូលបានគ្រប់គ្រាន់។

## ៣.៧. បទពិសោធន៍ដាំដំណាំខ្នុរឱ្យបានផ្លែច្រើន

លោកពូ លុយ ទូន ជាកសិកររស់នៅភូមិអូរស្ទើន ឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ ខេត្តតាកែវ។ គាត់មានមុខរបរធ្វើស្រែ និងដាំដំណាំ។ គាត់មានបទពិសោធន៍ច្រើនលើដំណាំឈើហូបផ្លែដូចជា ខ្នុរ ល្ហុង ធូរេន។ល។ បទពិសោធន៍ទាំងនេះគាត់បានចេះពីអ្នកជិតខាងរបស់គាត់ គួបផ្សំ និងការច្នៃប្រឌិតរបស់គាត់ថែមទៀត ធ្វើឱ្យការដាំដុះរបស់គាត់ទទួលបានផលល្អ។ នៅពេលនេះ ខ្ញុំសូមលើកយកបទពិសោធន៍ដាំខ្នុរ និងល្ហុងរបស់គាត់មកបង្ហាញជូនដូចខាងក្រោម ៖

### ក. ការជ្រើសរើសពូជ

ចំពោះដំណាំខ្នុរ គាត់បានជ្រើសរើសពូជពីផ្លែដែលទំហំធំ រសជាតិផ្អែម ក្លែបច្រើន និងសាច់ក្រាស់ គ្មានការបំផ្លាញពីជំងឺ និងសត្វល្អិត។ គ្រាប់ដែលគាត់យកធ្វើជាពូជដាំគឺពុះយកផ្នែកខាងកន្ទុយនៃផ្លែ។ តាមបទពិសោធន៍របស់គាត់កន្លងមកគឺយកគ្រាប់ ផ្នែកខាងកន្ទុយយកទៅបណ្តុះ និងដាំដើមដុះលូតលាស់ល្អ ឆាប់ផ្លែ និងមានផ្លែច្រើន។ ចំណែកខាងក្បាលវាដុះលូតលាស់ដែរ តែក្រផ្លែ ហើយមិនសូវមានផ្លែច្រើន។

### ខ. ការរៀបចំបណ្តុះគ្រាប់

គ្រាប់ដែលបានជ្រើសរើស (ប្រឡេះចេញពីផ្លែភ្លាម) គាត់យកទៅ ត្រាំទឹកទុក ១ យប់ ទើបយកទៅដាក់បណ្តុះនៅក្នុងថង់។ ថង់បណ្តុះគ្រាប់ គាត់រៀបចំជាស្រេចដោយដាក់ដីមានជីជាតិ ឬដីដំបូកលាយជាមួយជីកំប៉ុស្ត។ រួចកប់គ្រាប់នៅក្នុងថង់ មិនឱ្យលិចជ្រៅទេ បន្ទាប់មកស្រោចទឹកឱ្យជោគជារៀងរាល់ថ្ងៃ (១ថ្ងៃ ២ដង ព្រឹក-ល្ងាច) រហូតដល់កូនខ្នុរធំ អាយុបាន ៥-៦ ខែ គាត់ យកទៅដាក់ដាំក្នុងរណ្តៅ។

គ. ការរៀបចំរណ្តៅដាំ

នៅក្នុងចំការ គាត់កាប់រណ្តៅដាំដែលមានទំហំកន្លះម៉ែត្រ បួនជ្រុង ជំរៅកន្លះម៉ែត្រ និងចំងាយពីរណ្តៅមួយទៅមួយ ១ម៉ែត្រ។ គាត់កាប់រណ្តៅហាលចោលរយៈពេល ១៥ ថ្ងៃ ទើបដាក់ជីកំប៉ុស្តនិងសំរាមផ្សេងៗចូល ហើយកប់ដីស្រោចទឹកទុកឱ្យកំទេចសំរាមរលួយទើបកាយដីរណ្តៅដាក់កូនខ្នុរដាំ (នៅពេលយកកូនទៅដាំ គាត់ហែកស្បោងមិនឱ្យដាច់ឫសខ្នុរទេ)។

ឃ. ការថែទាំ

ក្រោយពីដាំហើយ គាត់ធ្វើការស្រោចទឹកជារៀងរាល់ថ្ងៃ ព្រមទាំងបោចស្មៅ ពូនគល់ និងដាក់ជីបំប៉ន (ជីកំប៉ុស្ត) រយៈពេល ៦ ខែម្តង នៅជុំវិញគល់ (ជីករណ្តៅជារង្វង់ចំងាយ ០.៥ម៉ែត្រពីគល់)។ លុះខ្នុរមានកម្ពស់ត្រឹមក្បាលមនុស្ស គាត់ចាប់ផ្តើមក្រៀវឱ្យមានកម្ពស់នៅត្រឹមចិញ្ចើមយើងរហូត។ ការក្រៀវនេះគឺ ដើម្បីរក្សាឱ្យខ្នុរមានដើមទាប ឆាប់ផ្លែ និងបែកមែក ផ្លែឱ្យបានច្រើន។ តាមបទពិសោធន៍របស់គាត់កន្លងមកដើមខ្នុរដែលមិនបានក្រៀវ វាចាប់ផ្លែយឺតជាងដើមដែលបានក្រៀវពី ២-៣ ឆ្នាំ។ ចំពោះបច្ចេក ទេសនៃការក្រៀវត្រូវយកឧបករណ៍ (កន្ត្រៃ) ស្អាតគ្មានច្រេះ និងមុតល្អដើម្បីកុំឱ្យឆ្លងជំងឺចូល។

ម្យ៉ាងទៀត ក្នុងការដាំដុះដំណាំខ្នុរតែងជួបប្រទះនូវសត្វដួងចោះចូលស៊ីក្នុងដើម គាត់កំចាត់សត្វល្អិតនេះ ដោយយកសាប៊ូលាយទឹកសុទ្ធរួចបាញ់បញ្ចូលក្នុងរន្ធរបស់វា។ ការដាំតាមបច្ចេកទេសបែបនេះធ្វើឱ្យខ្នុរឆាប់ផ្លែដាំតែរយៈពេល ៣ ឆ្នាំ ខ្នុរមានផ្លែ ផ្លែច្រើន និងមានរសជាតិផ្អែមឆ្ងាញ់។

## ៣.៨. បទពិសោធន៍ដាំដើមត្របែក

លោកពូ សុខ ខំ អាយុ ៥២ ឆ្នាំ ជាកសិករ រស់នៅភូមិរមូល ឃុំរមូល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។ គាត់មានបទពិសោធន៍ល្អក្នុងការដាំដុះដំណាំត្របែក និងទទួលបានផលរយៈពេលបីឆ្នាំមកហើយ បទពិសោធន៍នេះជាគំនិតច្នៃប្រឌិតរបស់គាត់ផ្ទាល់ ។



ដំណាំត្របែកកំពុងចាប់ផ្តើមផ្តល់ផល

ក្នុងលេខនេះ ខ្ញុំសូមលើកយកនូវបទពិសោធន៍របស់គាត់មកបង្ហាញជូនបងប្អូនកសិករទុកជាគំនិតសាកល,ងតាមដូចខាងក្រោមៈ

ក. ការត្រៀមពូជដាំ និងការបណ្តុះគ្រាប់

- ជ្រើសរើសប្រភេទពូជណាដែលមានផ្លែមូល (រាងដូចផ្លែក្រសាំង) និងជាពូជសំបូរផ្លែ ផ្តល់ទិន្នផលខ្ពស់
- យកផ្លែត្របែកដែលទុំស្រគៀល មកចិតយកសំបកចេញ ទុកតែគ្រាប់ដែលជាប់សាច់ រួចច្រកចូលទៅក្នុងថង់ប្លាស្ទិច ហើយរក្សាទុករយៈពេលពី ២៤ ម៉ោង ទៅ ៣៦ ម៉ោង ដើម្បីឱ្យហាប់ ឆាប់រលួយ ទើបយកទៅច្របាច់លាងទឹកឱ្យស្អាតនៅសល់តែគ្រាប់ រួចយកទៅហាលថ្ងៃឱ្យស្ងួត (ហាលនៅម៉ោង ៧-៩ ព្រឹក) ។
- យកគ្រាប់ត្របែកទៅបណ្តុះនៅលើរានដែលមានលាយដី (១០ ភាគ) ជាមួយលាមកសត្វ (៣ ភាគ) ផេះអង្កាម (៣ ភាគ) ច្របល់ចូលគ្នាឱ្យសព្វ
- យកគ្រាប់ត្របែកទៅរោយនៅលើរានលៃយ៉ាងណា កុំអោយក្រាស់ពេករួចយកជីលាមកសត្វទៅរោយពីលើគ្រាប់ស្តើងៗ បន្ទាប់មកយកកំទេចចំបើងទៅរោយពីលើបន្ថែមទៀត
- ក្រោយពីបណ្តុះគ្រាប់ហើយ ធ្វើការស្រោចទឹកអោយបានជោគ (ស្រោច ២ដង ក្នុង ១ ថ្ងៃ) ។

នៅពេលត្របែកមានអាយុ ៣០ ថ្ងៃ គាត់គាស់កូនយកទៅផ្សាំនៅក្នុងថង់ ១ សារទៀត រហូតដល់កូនត្របែកមានកំពស់ ៧-១០ សង្ទីម៉ែត្រ ទើបផ្ទេរយកទៅដាំក្នុងចំការ ។

## ខ. ការផ្សាំកូនត្របែក ឬស្ទុំកូនត្របែក

<u>ការរៀបចំដីដាក់ក្នុងថង់:</u> យកដីដែលមានជីជាតិ (១០ ភាគ) ទៅហាលថ្ងៃអោយស្ងួតល្អ លាយជាមួយផេះអង្កាមចំនួន (៥ ភាគ) ច្របល់ចូលគ្នាឱ្យសព្វ រួចច្រកចូលក្នុងថង់ដែលមានទំហំ (៧ ខ ១០ សង្ទីម៉ែត្រ) ។

<u>ការដកកូនយកមកផ្សាំ:</u> កូនត្របែកដែលដកយកទៅផ្សាំក្នុងថង់ ត្រូវកាត់ចុងឫសប្រវែង ១ ភាគ ៥ ចោល ។ ការផ្សាំត្រូវដាក់ក្រោមម្លប់ឈើ ដើម្បីការពារកំដៅថ្ងៃកុំឱ្យអន់ដើម ។ បន្ទាប់មក ស្រោចទឹកក្នុងមួយថ្ងៃ ៣ ដង រហូតដល់ត្របែកដុះត្រួយថ្មី ទើបបន្ថយការស្រោចទឹកនៅមួយថ្ងៃ ២ ដង. បន្ទាប់ពីដុះត្រួយថ្មីហើយ ត្រូវយកកូនត្របែកទាំងនោះទៅដាក់នៅក្រោមកំដៅថ្ងៃវិញ ដើម្បីអោយវាដុះលូតលាស់ល្អ ។ នៅពេលត្របែកដុះបានកំពស់ ៣០ សង្ទីម៉ែត្រ អាចយកវាទៅដាំក្នុងចំការបាន ។

## គ. ការរៀបចំរណ្តៅ និងការដាំ

ក្នុងការដាំ គាត់ជ្រើសរើសដីដែលមិនជាំទឹក ព្រោះត្របែកមិនត្រូវការលូតលាស់លើដីជាំទឹក ។ មុននឹងដាំ គាត់ធ្វើការភ្ជួរដីឱ្យបាន ២-៣ដង ហើយហាលដីរយៈពេល ១-២ សប្តាហ៍ទើបជីករណ្តៅដាំ ។ រណ្តៅមាន ទំហំ ៤តឹកបួនជ្រុង និងជំរៅ ៤ តឹក (ទំហំរណ្តៅនេះសំរាប់ដីដែលយើងភ្ជួររួច) ។ ចំពោះដីដែលមិនទាន់ភ្ជួរវិញ គាត់ ជីកទំហំ ៦តឹកបួនជ្រុង និងជំរៅ ៦តឹក (ព្រោះដីមិនបានភ្ជួរគឺមិនផុសល្អដូចដី ដែលភ្ជួររួចនោះទេ) ។ បន្ទាប់ពីជីករណ្តៅរួច គាត់ហាលរណ្តៅចោលរយៈពេល ៧-១០ថ្ងៃសិន ទើបប្រមូលជីលាមកសត្វពុកផុយ ឬ ជីកំប៉ុស្តទៅដាក់ក្នុង រណ្តៅ ដោយមួយរណ្តៅមានចំនួន ១០គីឡូក្រាម រួចហើយយកដីលុបពីលើមាត់រណ្តៅ ។ យកកូនត្របែកដាក់ដាំក្នុងរណ្តៅ ដោយហែកថង់

ចេញរួចបុកដីជុំវិញឱ្យណែន ។ មាត់រណ្តៅធ្វើជារាងកំពែង ដើម្បីឱ្យទឹកដក់ក្នុងរណ្តៅ ម្យ៉ាងទៀត ជីនៅបាតរណ្តៅឆាប់រលួយ ។

ឃ. ការថែទាំ

ដើម្បីឱ្យត្របែកដុះលូតលាស់បានល្អ គាត់ស្រោចទឹករាល់ពីរថ្ងៃម្តង ( ប្រមាណ ១០-១៥ លីត្រ ក្នុងមួយដើម) និងឪស្សាហ៍កិ្តចត្រួយចោលនៅពេលដែលត្របែកលាស់ត្រួយថ្មី ។ ការធ្វើបែបនេះ ដើម្បីឱ្យត្របែកអាចបែកមែក និងមានផ្លែច្រើនទៀតផង. ក្រៅពីក្តិចត្រួយ មានការដាក់ជីបំប៉នដែលធ្វើឡើងនៅពេលត្របែកជិតចេញផ្កា ដោយប្រើជីលាមកសត្វ កំប៉ុស្តក្នុងមួយរណ្តៅប្រមាណ ៣ គីឡូក្រាម ។ ក្រោយពេលប្រើជីបំប៉នបានរយៈពេល ១៥ ថ្ងៃ គាត់ស្រោចទឹកនោមលាយជាមួយទឹកធម្មតា ( ទឹកធម្មតា ១ លីត្រ លាយទឹកនោម ០.៥ លីត្រ) ក្នុង ១ ដើម ដើម្បីបំប៉នឱ្យការលូតលាស់រឹតតែបានល្អ ។

ដើម្បីរក្សាផ្លែត្របែកឱ្យមានពណ៌ស្អាតល្អ និងមិនមានការបំផ្លាញពីសត្វល្អិត គាត់បានយកក្រណាត់ទេសឯកដែលមានពណ៌សមកដេរធ្វើជាថង់រួចយកទៅជ្រលក់ជាមួយទឹកសាប៊ូ ហើយហាលថ្ងៃឱ្យស្ងួតសំរាប់ច្រកផ្លែត្របែក ( ច្រកផ្លែដែលមានទំហំប៉ុនពងទា) ។

ក្នុងការកំចាត់សត្វល្អិតបំផ្លាញត្របែក គាត់បានបំពួកភ្លើងនៅពេលល្ងាច ដោយប្រើស្លឹកស្ដៅ ស្លឹកគ្រៃ ស្លឹកហៃសាន និងស្លឹកម្រះព្រៅពីលើ ។ ព្រោះពពួកស្លឹកទាំងអស់នេះនៅពេលដុតផ្សែងរបស់វាបញ្ចេញក្លិន អាក្រក់ដែលធ្វើឱ្យសត្វល្អិតហើរចេញ ។ ក្រៅពីបំពក់ភ្លើង គាត់ព្រលែងមាន់ឱ្យដើរចឹកស៊ីសត្វល្អិតនៅក្រោមដើមត្របែក និងដាំដើមម្ទេស ដើមី,ទាក់ទាញចាបអោយចុះមកចឹកស៊ីដង្កូវ ។ ក្រៅពីវិធីសាស្ត្រខាងលើ គាត់បានប្រើថ្នាំផ្សំពីរុក្ខជាតិក្នុងមួយសប្តាហ៍ម្តង ។ ថ្នាំពុលផ្សំពីរុក្ខជាតិផ្សំឡើងពីរុក្ខជាតិដូចខាងក្រោមៈ

ធាតុផ្សំមានដូចជាៈ ទឹកនោម ១០ លីត្រ ថ្នាំខ្លាំង ៤ គីឡូក្រាម ដើមម្រះព្រៅ ២ គីឡូក្រាម សំបកស្ដៅ ២ គីឡូក្រាម សំបកហៃសាន ២ គីឡូក្រាម និងស្លឹកគ្រៃ ២ គីឡូក្រាម ទឹកធម្មតា ៣០ លីត្រ ។

របៀបផ្សំៈ យកសារធាតុទាំងអស់ទៅលាយបញ្ចូលគ្នាអោយសព្វ ដាក់ចូលទៅក្នុងពាងរួចចាក់ទឹកធម្មតា និងទឹកនោមចូលទៅក្នុងពាងបិទគ្របពីលើឱ្យជិត ។ រក្សាទុកក្រោមម្លប់ឈើរយៈពេល ៣០ ថ្ងៃ អាចយកទៅប្រើប្រស់បាន. ក្នុងកំឡុងពេលរក្សាទុក ត្រូវធ្វើការកូរ ១ ថ្ងៃម្តង ។

របៀបប្រើៈ ទឹក ១០ លីត្រ សាប៊ូមួយស្លាព្រាចយ ទឹកថ្នាំមួយកំប៉ុងទឹកដោះគោ លាយចូលគ្នាអោយសព្វរួចយកទៅបាញ់លើត្របែករាល់មួយសប្តាហ៍ម្តង. ( បើមានការបំផ្លាញច្រើន ត្រូវបាញ់ចំនួន ២-៣ ដង ក្នុង ១សប្តាហ៍ ) ។

ង. ការប្រមូលផល

ក្រោយពីដាំបានរយៈពេល ១១ ខែ ត្របែកអាចប្រមូលផលបាន ។ នៅលើផ្ទៃដីចំនួន ១០ អារ (ដាំត្របែកបានដើម) គាត់អាចប្រមូផលបានចំនួន ៣ លើក។ នៅឆ្នាំទី ១ ប្រមូលផលបានចំនួន ១.២ តោន នៅឆ្នាំទី ២ ប្រមូលផលបាន ២ តោន នៅឆ្នាំទី ៣ ប្រមូលផលបាន ២.៥ តោន ។ ត្របែក ១ គីឡូក្រាម លក់បានតំលៃពី ១០០០ ទៅ ១៥០០ រៀល។

ក្នុងការប្រមូលផល គាត់យកកូនកន្ត្រៃទៅកាត់ទង (បើប្រើដៃវាអាចធ្វើអោយបាក់បែក ឬរាំហែកសំបកដើម នាំឱ្យកើត ជំងឺ) ។ ក្រោយពីទទួលផលបាន ៣ ដង មក គាត់ក៏មានការពេញចិត្តជាខ្លាំង ដោយសារគាត់ទទួលបានប្រាក់ចំណូលច្រើន ព្រោះមិនចំណាយទុនច្រើនលើការទិញជី និងថ្នាំពុលគីមី ។

ច. ចំណាប់អារម្មណ៍

សរុបមកបច្ចេកទេសសំខាន់ៗ ក្នុងការដាំត្របែកមានៈ

- ជ្រើសរើសពូជដែលមានផ្លែមូល និងទិន្នផលខ្ពស់
- យកគ្រាប់ទៅបណ្តុះនៅលើរានដែលលាយដីមានជីជាតិ និងផេះអង្កាម
- ដកកូនពីថ្នាលបណ្តុះយកទៅផ្សាំក្នុងថង់ ១ សារទៀត ដីម៉ីឱ្យកូនត្របែករឹងមាំ និងលូតលាស់ល្អ ទើបយកទៅដាំនៅក្នុងចំការ
- ជីករណ្តៅដាំ ដោយដាក់លាមកសត្វ និងជីកំប៉ុស្តកប់នៅបាតរណ្តៅ
- ថែទាំស្រោចទឹក ក្តិចត្រួយ និងស្រោចទឹកនោមបប៉ន
- ការពារសត្វបំផ្លាញ ដោយប្រើថ្នាំផ្សំពីរុក្ខជាតិ ដុតបំពក់រុក្ខជាតិដែលមានក្លិនអាក្រក់ ដើម្បីបណ្តេញសត្វល្អិត ព្រលែងមាន់ឱ្យចឹកស៊ីសត្វល្អិត
- ប្រមូលផលដោយយកកន្ត្រៃទៅកាត់ទង ។

កំណត់សំគាល់បន្ថែមពីអង្គការសេដាក យកល្អកុំប្រើថ្នាំជក់ ពីព្រោះវាមានជាតិពុលខ្លាំង អាចគ្រោះថ្នាក់ដល់សុខភាព។

### ៣.៩. បទពិសោធន៍ដាំដូងឆាប់ផ្លែ ហើយផ្លែបានច្រើន

តាមបទពិសោធន៍ ពីកសិករម្នាក់ឈ្មោះ **បាស់ កាប់ហៃ សារី** ដែលជាកសិករឥណ្ឌា គាត់អាចដាំដូងមួយដើមបានផ្លែរហូតដល់ ៤០០ផ្លែក្នុង ១ឆ្នាំ។ ណាមួយទៀត ដូងរបស់គាត់ចាប់ផ្តើមផ្លែនៅពេលអាយុបាន **៣ឆ្នាំ**។

ផលដែលគាត់ទទួលបាននេះ វាមិនមែនធម្មតាទេ វាជាផលមួយដែលខ្ពស់បំផុតនៅប្រទេស ឥណ្ឌា ហើយវាក៏អាចជាផលមួយខ្ពស់ណាស់ដែរនៅប្រទេសខ្មែរ។ ដោយ យល់ដូចនេះហើយ ទើបខ្ញុំចុះផ្សាយនូវបច្ចេកទេសរបស់គាត់ដើម្បីផ្តល់ជាគំនិតសំរាប់លោក-អ្នក យកទៅសាក ល្បងតាម។

តាមបទពិសោធន៍របស់គាត់ ដើម្បីដាំដូង គេកាប់ រណ្តៅទំហំ ១ម៉ែត្រ ៤ជ្រុង និងជំរៅ ១ម៉ែត្រ។ នៅក្នុងរណ្តៅគេដាក់សារធាតុផ្សេងៗតាមលំដាប់ ដូចរៀបរាប់ខាង ក្រោមនេះ ( សូម មើលរូបភាពបន្ថែម)

- បាតក្រោម គេដាក់កន្ទក់ ឬអាចម៍រណារកំរាស់ ២ តឹកកន្លះ (២៥ សង់ទីម៉ែត្រ)
- បន្ទាប់មក គេដាក់ដីស្រទាប់លើកំរាស់ ១តឹកកន្លះ ( ១៥សង់ទីម៉ែត្រ)
- ស្រទាប់ទី ៣ គេដាក់ដីខ្សាច់កំរាស់ ១តឹកកន្លះ ( ១៥សង់ទីម៉ែត្រ)
- ស្រទាប់ទី ៤ គេដាក់អាចម៍គោកំរាស់ ១តឹកកន្លះ ( ១៥សង់ទីម៉ែត្រ)
- ស្រទាប់លើបំផុត គេដាក់ដីខ្សាច់កំរាស់ ២តឹកកន្លះ ( ២៥សង់ទីម៉ែត្រ)

ស្រទាប់និមួយៗ មានសារៈសំខាន់ផ្សេងៗគ្នា

- កន្ទក់ ឬអាចម៍រណារ ជាសារធាតុក្រពុក ដូចនេះនៅពេលប្រហែល ២ឆ្នាំក្រោយមកវានឹងពុកល្អ ។ ទំរាំដល់ពេលនោះឫសដូងនឹងចាក់ទៅដល់ ហើយអាចស្រូបយកជីតែម្តង ។
- ដីស្រទាប់លើប្រើដើម្បីជួយឱ្យកន្ទក់ ឬអាចម៍រណារឆាប់ពុក ដោយក្នុងដីស្រទាប់លើមានសត្វល្អិត ឬមីក្រូសរីរាង្គរស់នៅច្រើន ( សត្វដែលជាអ្នកធ្វើឱ្យកន្ទក់ឆាប់ពុក)
- ដីខ្សាច់ប្រើសំរាប់ជួយឱ្យដីធូរ មានខ្យល់ចេញចូលបានល្អ ហើយការពារកុំឱ្យជាំទឹក
- អាចម៍គោ ដែលនៅស្រទាប់ទី ៤ នៅចន្លោះស្រទាប់ដីខ្សាច់ នៅពេលរលួយក្លាយទៅជាជីសំរាប់ដូង ។ ក្រៅ ពីនោះ វាជួយដល់ការរក្សាសំណើមបានល្អថែមទៀតផង ។




ចំពោះការជ្រើសរើសពូជ គាត់យកផ្លែណាដែលមានសំបកខាងក្រៅរាងរលោង ហើយមានផ្លែធ្ងន់ល្អ ពីព្រោះគាត់យល់ថា ផ្លែរបៀបនេះ ជាផ្លែដែលកើតមកពីបង្កាត់លំអងគ្រប់លក្ខណៈ ។ កូនដូងដែលយកទៅដាំ ត្រូវមានសន្លឹកយ៉ាងតិចបំផុត ៦ នៅពេលវាមានអាយុ ១ឆ្នាំ ឬមានសន្លឹក ៤ យ៉ាងតិចបំផុត នៅពេលវាមានអាយុ ៩ខែ ទើបយកទៅដាំ។ កូនដូងដែលបំពេញលក្ខណៈរបៀបនេះ គេយកទៅដាំក្នុងរណ្តៅ គឺដាក់នៅលើស្រទាប់ខ្សាច់ខាងលើតែម្តង ។

តាមការបកស្រាយខាងលើ ឃើញថាបទពិសោធន៍នេះហាក់ដូចជាល្អម្យ៉ាងដែរ ។ ដូចនេះប្រសិនបើលោក-អ្នកមានការចាប់អារម្មណ៍ ហើយចង់ដឹងការពិតមានតែធ្វើការសាកល្បងមើលសិន ។

# ជំពូក ៤

# សង្ខេបបច្ចេកទេសសំខាន់ៗក្នុងការដាំឈើហូបផ្លែ

ឈើហូបផ្លែជាដំណាំ ដែលមានលក្ខណៈយូរអង្វែង (ច្រើនឆ្នាំ) ដូច្នេះក្នុងការដាំដុះកសិករតែងតែមានការយកចិត្តទុកដាក់ខ្លាំងពីដំបូង ដូចជាការជ្រើសរើសដីដាំ ការកាប់រណ្ដៅដាំ និងការថែទាំ។ល។ ជាទូទៅចំណុចដែលកសិករយកចិត្តទុកដាក់មាន៖

- ជ្រើសរើសកន្លែងដាំនៅលើដីទួល មិនលិចទឹក
- រៀបចំរណ្ដៅដាំ ដោយមានទំហំធំ (១ម៉ែត្រ ៤ជ្រុង) និងជំរៅ ១ម៉ែត្រ
- ដាក់សារធាតុសរីរាង្គ (លាមកសត្វ កំប៉ុស្ដ សំរាម ស្លឹកឈើ) ទៅតាមស្រទាប់
- បណ្ដុះកូនពីគ្រាប់ យកទៅដាំច្រើនជាងប្រើមែកផ្សាំ ព្រោះកូន ដែលដុះពីគ្រាប់ទទួលបានផលរយៈពេលយូរជាង
- កាប់រណ្ដៅដាំជារាងកំពែងដើម្បីឱ្យទឹកដក់បន្តិច មិនហូរច្រោះនៅពេលស្រោចទឹក
- ចាប់ដាំនៅដើមរដូវភ្លៀងដើម្បីកាត់បន្ថយការស្រោចទឹក
- ដាក់ជីដោយកាប់ជាចង្អូររង្វង់នៅជុំវិញដើមឱ្យនៅចំចុងមែករបស់ដើម
- ដាក់ជីធម្មជាតិនៅក្នុងចង្អូរ និងលុបដីពីលើ (ការដាក់ជីធ្វើឡើងរៀងរាល់ឆ្នាំ)
- ស្រោចទឹក ២-៣ថ្ងៃម្ដងពេលកូនឈើនៅតូច
- ធ្វើការថែទាំផ្សេងៗ ដូចជាការកាត់តែងមែកដើម្បីឱ្យដើមឈើទទួលបានពន្លឺគ្រប់គ្រាន់ និងបំផ្លាញជំរកសត្វល្អិត និងជំងឺ។

# ឯកសារយោង

១. Angel C. Alcala, 1992, Trees and Their Management

២. Agriund Cambodia, 1999, Arobrienltune Fruit Tree

៣. CEDSE, 1997, Fruit Tree

៤. សមរិទ្ធ និងស៊ឹម សាមឿន, ២០០៩, ការបណ្តុះ និងដាំកូនឈើ, សេដាក

៥. Ardhendus. CHATTERTEE, 1997, Fruit Tree in Cambodia Home Garden, Tre/JVC Cambodia